SBI LH

# ធនាគារ អេស ប៊ី អាយ លី ហួរ
## SBI LY HOUR Bank



# របាយការណ៍ប្រចាំឆ្នាំ ២០២០



SBI LH
ធនាគារ អេស ប៊ី អាយ លី ហួរ
SBI LY HOUR Bank

# មាតិកា


## ០១ អំពីធនាគារ

ទំព័រ ១ - ២៨

អំពីធនាគារ
ទិន្នន័យសំខាន់ៗ
ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ
ស្ថាប័នផ្តល់ហិរញ្ញប្បទានដល់ ធនាគារ
សាររបស់ប្រធានក្រុមប្រឹក្សាភិបាល
សាររបស់លោកអគ្គនាយក
ក្រុមប្រឹក្សាភិបាល
គណៈគ្រប់គ្រងជាន់ខ្ពស់
រចនាសម្ព័ន្ធគណៈគ្រប់គ្រង
ការគ្រប់គ្រងហានិភ័យ
ធនធានមនុស្ស
អំពីផលិតផល និងសេវាកម្ម

## ០២ របាយការណ៍ហិរញ្ញវត្ថុ

ទំព័រ ៣០ - ៤២

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
របាយការណ៍របស់សវនករឯករាជ្យ
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
របាយការណ៍លំហូរទឹកប្រាក់

## ០៣ បណ្តាញការិយាល័យទំនាក់ទំនង

ទំព័រ ៤៤ - ៤៨

ការិយាល័យស្នងដារ
បណ្តាញសាខា

០១

# អំពីធនាគារ


អំពីធនាគារ ០២
ទិន្នន័យសំខាន់ៗ ០៣
ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ ០៥
ស្ថាប័នផ្តល់ហិរញ្ញប្បទានដល់ ធនាគារ ០៦
សាររបស់ប្រធានក្រុមប្រឹក្សាភិបាល ០៧
សាររបស់លោកអគ្គនាយក ០៩
ក្រុមប្រឹក្សាភិបាល ១១
គណៈគ្រប់គ្រងជាន់ខ្ពស់ ១៥
រចនាសម្ព័ន្ធគណៈគ្រប់គ្រង ២១
ការគ្រប់គ្រងហានិភ័យ ២៣
ធនធានមនុស្ស ២៥
អំពីផលិតផល និងសេវាកម្ម ២៧

# អំពីធនាគារ



ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក គឺជាការបណ្តាក់ទុនរួមគ្នារវាងអ្នកឧកញ៉ា លី ហួរ និងក្រុមហ៊ុន SBI Holdings Inc.។ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក គឺជាក្រុមហ៊ុនត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ទស្សនៈវិស័យរបស់ធនាគារគឺផ្តល់ជូននូវអាជីវកម្មធនាគារពាណិជ្ជកម្មដល់បុគ្គល សហគ្រាសធុនតូច និងមធ្យម ក្រុមហ៊ុន និងសាជីវកម្មជាទូទៅដើម្បីចូលរួមចំណែកក្នុងការ អភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងទៀតដែលអនុវត្ត ដោយធនាគារពាណិជ្ជកម្មអន្តរជាតិទាំងអស់។ គោលបំណងគឺដើម្បីជួយដល់ប្រទេសកម្ពុជា អាជីវកម្ម និងប្រជាជនកម្ពុជាដើម្បី លើកកម្ពស់ជីវភាពរស់នៅ និងការរីកចម្រើនអាជីវកម្មដោយផ្តល់ជូននូវសេវាកម្មធនាគារដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ បច្ចេកវិទ្យាជឿនលឿនការផ្តល់ហិរញ្ញប្បទានដែលមាន តម្លៃសមរម្យ និងនាំមកនូវបច្ចេកវិទ្យាហិរញ្ញវត្ថុចុងក្រោយដើម្បីផ្តល់បទពិសោធន៍ដល់អ្នកប្រើប្រាស់កាន់តែងាយស្រួល និងមានភាពទាក់ទាញ។



# ទិន្នន័យសំខាន់ៗ




ប្រាក់ចំណេញសុទ្ធ/ ខាត
(គិតជាលានដុល្លារអាមេរិក)




ផលប័ត្រប្រាក់កម្ចី
(គិតជាលានដុល្លារអាមេរិក)




ទ្រព្យសកម្មសរុប
(គិតជាលានដុល្លារអាមេរិក)






មូលធនសរុប
(គិតជាលានដុល្លារអាមេរិក)




ចំណូលការប្រាក់
(គិតជាលានដុល្លារអាមេរិក)




ប្រាក់ចំណេញសុទ្ធប្រៀប
និងមូលធន




កំណើនសំពៀតឥណទាន




ផលប័ត្រប្រាក់កម្ចីមាន
ហានិភ័យធំជាង ៣០ថ្ងៃ




ទំហំសំពៀតឥណទានមធ្យម





# ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ



## ចក្ខុវិស័យ

ធនាគារឈានមុខគេប្រកបដោយការជឿជាក់ជាមួយនវានុវត្តន៍ហិរញ្ញវត្ថុ តាមរយៈការបន្តអភិវឌ្ឍខ្លួនប្រកបដោយទំនួលខុសត្រូវផ្នែកសង្គម។

## បេសកកម្ម

ជម្រុញ និងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធធនាគារឌីជីថលដ៏ទំនើប ប្រតិបត្តិការធនាគារដែលមានទំនុកចិត្ត និងបណ្តាញភ្នាក់ងារក្នុងព្រះរាជាណាចក្រកម្ពុជា។

## គុណតម្លៃ

សុចរិតភាព៖ ការប្រព្រឹត្តត្រឹមត្រូវ និងស្មោះត្រង់
ភាពជាអ្នកដឹកនាំ ៖ ទាំងអស់គ្នាជាអ្នកដឹកនាំ
សហប្រតិបត្តិការ ៖ រួមគ្នាសម្រេចគោលដៅ
ការទទួលខុសត្រូវ៖ ខ្ញុំធ្វើ គឺខ្ញុំទទួលខុសត្រូវ
អតិថិជនជាចម្បង៖ សេវាកម្មល្អឥតខ្ចោះ

# ស្ថាប័នផ្តល់ហិរញ្ញប្បទានដល់ ធនាគារ

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ពីមុនត្រូវបានស្គាល់ថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី បានផ្លាស់ប្តូរទៅជាធនាគារពាណិជ្ជនៅដើមឆ្នាំ ២០២០។ ធនាគារបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០០១៣១៣ ដែលបានចុះបញ្ជីកាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២ ដោយមានដើមទុនចំនួន ៧៥ លានដុល្លារ។ ធនាគារទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ និងមានទីស្នាក់ការកណ្តាលនៅអគារលេខ២១៩ ផ្លូវ១២៨ កែង១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ជាក្រុមហ៊ុនបណ្តាក់ទុនរួមគ្នារវាង SBI Holdings, Inc. (៧០%) និងអ្នកឧកញ៉ា លី ហួរ តំណាង លី ហួរ គ្រុប (៣០%)។

SBI Holdings, Inc. (ក្រុមហ៊ុនអភិវឌ្ឍអាជីវកម្មជាយុទ្ធសាស្ត្រ) ដែលបានបង្កើតឡើងនៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ១៩៩៩ គឺជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងផ្សារភាគហ៊ុននៃទីក្រុងតូក្យូ ប្រទេសជប៉ុន។ ក្រុមហ៊ុនមានទីស្នាក់ការកណ្តាលនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដែលបច្ចុប្បន្នមានក្រុមហ៊ុនចំនួន ៣០៣ ស្ថិតនៅក្នុង ២២ប្រទេស និងតំបន់នៅទូទាំងពិភពលោក។ ក្រុមហ៊ុននេះកំពុងប្រតិបត្តិការអាជីវកម្មជាសកលលើវិស័យសំខាន់ៗដូចជា សេវាកម្មហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងជីវបច្ចេកវិទ្យា ។ល។

ក្រុមហ៊ុន លី ហួរ គ្រុប បានបើកដំណើរការអាជីវកម្មចាប់តាំងពីឆ្នាំ១៩៨៦ ដែលបច្ចុប្បន្នមានក្រុមហ៊ុនធំៗចំនួន ០៨ រួមមាន៖

(១) ក្រុមហ៊ុន លី ហួរ អ៊ិចឆេង ឯ.ក
(២) ក្រុមហ៊ុន លី ហួរ ផនសប ខូអិលធីឌី
(៣) បុរី វិមានភ្នំពេញ
(៤) ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក
(៥) ក្រុមហ៊ុន ទេពី អាក្រូ វិនិយោគ
(៦) ក្រុមហ៊ុន លី ហួរ លីស៊ីង ភីអិលស៊ី
(៧)ក្រុមហ៊ុន លី ហួរ ផេប្រ៉ូ ភីអិលស៊ី
(៨)ក្រុមហ៊ុន លី ហួរ អ៊ិនស្ទួរេន ម.ក

ជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០២០ ហើយក៏កំពុងបន្តជះឥទ្ធិពលមិនល្អ។ ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នេះបានបណ្តាលឲ្យ មានការថយចុះយ៉ាងខ្លាំងនូវក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចភាគច្រើនរបស់កម្ពុជារួមមានវិស័យទេសចរណ៍ ការផលិតដើម្បីនាំចេញ និងវិស័យសំណង់។ ទោះបីជាមានវិបត្តិ កូវីដ-១៩ ក៏ដោយវិស័យធនាគារដែលមានការគាំទ្រជាយុទ្ធសាស្ត្រពីធនាគារជាតិនៃកម្ពុជា នៅតែបន្តមានស្ថិរភាព និងចូលរួមយ៉ាងសកម្មក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើអាជីវកម្ម និងប្រជាជនក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ស្របពេលគ្នានេះដែរធនាគារ អេស ប៊ី អាយ លី ហួរ ម.ក នៅឆ្នាំ ២០២០ បានក្លាយជាធនាគារមួយក្នុងចំណោមធនាគារធំៗក្នុងប្រទេសដែលមាន សកម្មភាពលេចធ្លោ និងគួរឲ្យកត់សម្គាល់ ដោយទទួលបានការទទួលស្គាល់ពីសាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីក្លាយជាធនាគារពាណិជ្ជ ហើយទោះបីជាស្ថិតនៅក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ ធនាគារមានកំណើនយ៉ាងខ្ពស់ ទាំងប្រាក់បញ្ញើសន្សំ និងឥណទាន។ ធនាគារបានពង្រីកការិយាល័យរបស់ខ្លួនចំនួន ៤០ សាខា (៦សាខា បន្ថែមទៀតក្រោមការបង្កើត និងដំណើរការអនុម័តផ្នែកច្បាប់) នៅទូទាំង ២៥ ខេត្តដែលមានបុគ្គលិកសរុប ១.១៥៧ នាក់ (បុគ្គលិក ៥៦០ ត្រូវបានជ្រើសរើសថ្មី) ។

ធនាគារបានបង្កើតក្រុមប្រឹក្សាភិបាលថ្មីរបស់ខ្លួន និងធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចរបស់ធនាគារដោយបង្កើតគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាលចំនួន ៣ រួមមាន៖ (១) គណៈកម្មការសវនកម្ម (២) គណៈកម្មការត្រួតពិនិត្យហានិភ័យ និង (៣) គណៈកម្មការតែងតាំង និងផ្តល់តម្លៃការដើម្បីអនុវត្តតាមបទប្បញ្ញត្តិ នៃ ធនាគារជាតិ នៃ កម្ពុជា និងធានាឲ្យបាននូវការអនុវត្តអភិបាលកិច្ចល្អ។ ជាមួយគ្នានេះដែរដោយមានប្រព័ន្ធគ្រប់គ្រងហានិភ័យដ៏រឹងមាំ ធនាគាររក្សាបាននូវគុណភាពផលប័ត្រឥណទានល្អដោយផលប័ត្រឥណទានមានហានិភ័យលើស៣០ថ្ងៃមានត្រឹមតែ ១% និង ០,៨៧% នៃឥណទានរៀបចំឡើងវិញ។ ធនាគារមិនបានធ្វើការលុបចោលនូវឥណទានដែលជាបំណុលអាក្រក់នោះទេ នៅក្នុងឆ្នាំ ២០២០ ។ ធនាគាររំពឹងថាអាជីវកម្មរបស់ធនាគារនឹងមានកំណើនកើនឡើងខ្ពស់នៅឆ្នាំ ២០២១។ ធនាគារប្តេជ្ញាពង្រីកសេវាកម្មរបស់ធនាគារនៅតាមតំបន់ជនបទ និងជ្រៀតចូលឲ្យបាន ៩៥% នៅគ្រប់ឃុំទាំងអស់ក្នុងប្រទេស តាមរយៈសាខារបស់ធនាគារ និងភ្នាក់ងារ លី ហួរ វេរលុយ ដែលជាទីកន្លែងដែលអតិថិជនអាចធ្វើប្រតិបត្តិការសាច់ប្រាក់។

តាងនាមឲ្យម្ចាស់ភាគហ៊ុន និងក្រុមប្រឹក្សាភិបាល ខ្ញុំសូមកោតសរសើរ សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២០ ដែលបានមកពីការចូលរួមគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់គ្រប់ភាគីពាក់ព័ន្ធរួមមាន ធនាគារដៃគូ អតិថិជន ក្រុមហ៊ុន សវនកម្មឯករាជ្យ និងរាជរដ្ឋាភិបាល ជាពិសេសធនាគារជាតិនៃកម្ពុជា។ សមិទ្ធផលទាំងអស់នេះ នឹងមិនអាចសម្រេចបានឡើយ ប្រសិនបើមិនមានការចូលរួមគាំទ្រ ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់។ ជាចុងបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ដែលបានខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តខ្ពស់ចំពោះការអនុវត្តការងារពេញមួយឆ្នាំប្រកបដោយភាពជោគជ័យ។




**អ្នកឧកញ៉ា លី ហួរ**
**ប្រធានក្រុមប្រឹក្សាភិបាល**



# សាររបស់លោកអគ្គនាយក

***ឆ្នាំ២០២០ត្រូវបានគេកត់សំគាល់ថាជាជំពូកដំបូងនៃការផ្លាស់ប្តូរយ៉ាងពេញលេញពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្លាយទៅជាធនាគារមួយដែលមានភាពប្រកួតប្រជែងខ្លាំងក្នុងប្រទេសកម្ពុជា អំឡុងពេលជំងឺរាតត្បាតកូវីដ-១៩។***

នៅក្នុងបរិបទមួយដែលឥណទានរៀបចំឡើងវិញកើនឡើងលើសពី ៣ពាន់លានដុល្លារអាមេរិក ជាមួយនឹងអតិថិជនប្រមាណជាង៣០ម៉ឺននាក់ សម្រាប់វិស័យធនាគារទាំងមូលនៅឆ្នាំ២០២០ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក បានរៀបចំឥណទានឡើងវិញក្នុងអត្រា០,៦% និងគ្រប់គ្រងឥណទានយឺតយ៉ាវមកនៅត្រឹមអត្រា០,៩%តែប៉ុណ្ណោះ។ទោះជាជំងឺកូវីដ១៩បានបន្តរីករាលដាលពិតមែន ប៉ុន្តែធនាគារមានពេលវេលាគ្រប់គ្រាន់នៅឆ្នាំ២០២០ ក្នុងការរៀបចំបង្កើតការិយាល័យសាខាបន្ថែមទៀត ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាថ្មី ជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិករបស់យើង និងធ្វើបច្ចុប្បន្នភាពបន្ថែមចំពោះផលិតផល និងគោលនយោបាយរបស់យើង ដោយពួកយើងបានត្រៀមខ្លួនរួចជាស្រេចក្នុងការប្រកួតប្រជែងនៅឆ្នាំ២០២១។

ជាការពិតណាស់ការគ្រប់គ្រងហានិភ័យដើរតួយ៉ាងសំខាន់នៅក្នុងប្រតិបត្តិការធនាគារ ដែលយើងកំពុងផ្តោតការយកចិត្តទុកដាក់និងផ្តល់អាទិភាពយ៉ាងខ្លាំង។ ការគ្រប់គ្រងហានិភ័យគឺជាកាតាលីករដែលជួយឲ្យស្ថាប័នទាំងមូលឆ្ពោះទៅរកភាពជោគជ័យក៏ដូចជារក្សាបាននូវនិរន្តរភាពយូរអង្វែង។ ក្នុងចំណុចនេះផងដែរធនាគារបានបែងចែកមុខងារជាបីផ្នែកសំខាន់ៗដូចខាងក្រោម៖

១. មុខងារអាជីវកម្ម ៖ ការគ្រប់គ្រងហានិភ័យកម្រិតទី១គឺជាការគ្រប់គ្រងដោយស្វ័យប្រវត្តិក្នុងឋានានុក្រមអាជីវកម្ម។

២. មុខងារហានិភ័យ៖ ការគ្រប់គ្រងហានិភ័យកម្រិតទី២តាមរយៈការត្រួតពិនិត្យ និងធ្វើការវិភាគហានិភ័យដោយក្រុមការងារផ្នែកហានិភ័យ និងក្រុមការងារផ្នែកប្រតិបត្តិតាម។

៣. មុខងារសវនកម្ម ៖ ការគ្រប់គ្រងហានិភ័យកម្រិតទី៣ត្រូវបានបង្កើតឡើងដោយអ្នកត្រួតពិនិត្យទាំងអស់នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ជាមួយនឹងបទពិសោធន៍យូរអង្វែង ទៅលើផ្នែកធនាគារឌីជីថល និងបណ្តាញភ្នាក់ងារធនាគារ អនុញ្ញាតឲ្យយើងពង្រីកអាជីវកម្មរបស់យើងតាមភូមិសាស្ត្រ ដែលមានការចំណាយតិចនៅក្នុងទីផ្សារដ៏ធំនៃវិស័យមីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូចនិងមធ្យម។ ថ្មីៗនេះ លទ្ធផលប្រចាំថ្ងៃរបស់យើងឈានដល់ប្រមាណជាង ២ លានដុល្លារអាមេរិក សម្រាប់ទាំងការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់បញ្ញើសន្សំ ដោយធនាគាររំពឹងថានឹងបង្កើនបន្ថែមទៀតរហូតដល់ ៣លានដុល្លារអាមេរិកនៅឆ្នាំ ២០២១។ ធនាគារបានពង្រីកការិយាល័យរបស់ខ្លួនចំនួន៤០សាខានៅទូទាំង ២៥ ខេត្ត ក្រុង (៦សាខាបន្ថែមទៀត ស្ថិតក្នុងការរៀបចំ និងដំណើរការសុំការអនុម័ត)ដែលមានបុគ្គលិកសរុបចំនួន ១.១៥៧ នាក់ (បុគ្គលិក ៥៦០ នាក់ត្រូវបានជ្រើសរើសថ្មីក្នុងឆ្នាំ២០២០)។

ជាការពិតណាស់ការកម្លាយខ្លួនទៅរកធនាគារបែបប្រព័ន្ធឌីជីថលគឺជាការចាប់ផ្តើមអាជីវកម្មនិងចំណុចអាទិភាពមួយរបស់ធនាគារក្នុងគោលបំណងដើម្បីផ្តល់នូវគុណតម្លៃជូនអតិថិជន។ គោលដៅរបស់យើងក្នុងអាជីវកម្មបែបឌីជីថលគឺដើម្បីកែលំអនិងធ្វើទំនើបកម្មសេវាកម្មធនាគាររបស់យើងឈានមុខចំពោះបរិយាប័ន្នហិរញ្ញវត្ថុតាមរយៈម៉ាស៊ីនអេធីអឹម និងកម្មវិធីធនាគារចល័ត។ ក្នុងឆ្នាំ២០២១នេះផងដែរគឺជាឆ្នាំរបស់ធនាគារដែលនឹងចូលរួមយ៉ាងពេញលេញនៅក្នុងទីផ្សារឌីជីថល នៃវិស័យធនាគារនៅក្នុងប្រទេសកម្ពុជានិងដើម្បីត្រៀមខ្លួនសម្រាប់បដិវត្តឧស្សាហកម្ម ៤.០ ។

យុទ្ធសាស្ត្រសំខាន់របស់យើងគឺផ្តោតលើការប្រមូលប្រាក់បញ្ញើពីក្រុងភ្នំពេញ និងដើម្បីផ្តល់ប្រាក់កម្ចីនៅតាមតំបន់ជនបទក្នុង ២៥ខេត្ត-ក្រុង ដែលផ្តោតសំខាន់លើវិស័យមីក្រូហិរញ្ញវត្ថុនិងសហគ្រាសខ្នាតតូចនិងមធ្យម ដោយមានការគាំទ្រពីបណ្តាញភ្នាក់ងាររបស់ធនាគារ គឺ ភ្នាក់ងារ លី ហួរ វេរលុយ (ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់លី ហួរ គ្រុប) ជាង ៤.៥០០កន្លែងទូទាំងប្រទេស។ អតិថិជនរបស់យើងនឹងត្រូវបាន បណ្តុះបណ្តាលឲ្យធ្វើប្រតិបត្តិការធនាគារ សម្រាប់ការដកប្រាក់ និងការទូទាត់សងតាមរយៈកាតដោយផ្ទាល់។

ជាទីបញ្ចប់ តាងនាមឲ្យគណៈគ្រប់គ្រងនិងបុគ្គលិកទាំងអស់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិក ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលបានដឹកនាំ សហការ និងគាំទ្រប្រតិបត្តិការរបស់ធនាគារ។ ឆ្លៀតក្នុងឱកាសនេះផងដែរ សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា អាជ្ញាធរពាក់ព័ន្ធ និងអតិថិជនទាំងអស់ដែលតែងតែផ្តល់ទំនុកចិត្ត ការគាំទ្រ និងប្រើប្រាស់ រួមទាំងការធ្វើកិច្ចសហប្រតិបត្តិការជាមួយធនាគារ អេស ប៊ី អាយ លី ហួរ ម.ក។




**លោក អ៊ុត សឿង**
**អគ្គនាយក**




SBILH

# ក្រុមប្រឹក្សាភិបាល



## អ្នកឧកញ៉ា លី ហួរ

### ប្រធានក្រុមប្រឹក្សាភិបាល

អ្នកឧកញ៉ា លី ហួរ ជាស្ថាបនិកនៃក្រុមហ៊ុន លី ហួរ គ្រុប កើតនៅឆ្នាំ១៩៥៤ មានទីកន្លែងកំណើតនៅខេត្តកំពង់ចាម។

លោកចាប់ផ្តើមសម្ព័ន្ធអាជីវកម្មរបស់លោកពីមាសចំនួន ២ (ពីរ) ជីកន្លះ នៅដើមទសវត្សរ៍ទី៨០ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ សព្វថ្ងៃនេះ អ្នកឧកញ៉ា លី ហួរ គឺជាពាណិជ្ជករដ៏លេចធ្លោ និងគួរឲ្យទុកចិត្តបំផុតនៅប្រទេសកម្ពុជា។

នៅពីក្រោមចក្ខុវិស័យនៃភាពជាអ្នកដឹកនាំរបស់ អ្នកឧកញ៉ា លី ហួរ ក្រុមហ៊ុន លី ហួរ គ្រុប បានអភិវឌ្ឍន៍នូវមុខជំនួញហិរញ្ញវត្ថុជាច្រើនរួមមាន ក្រុមហ៊ុនប្តូរប្រាក់ ក្រុមហ៊ុនជួញដូរមាស ក្រុមហ៊ុនបញ្ចាំ ធនាគារពាណិជ្ជ ក្រុមហ៊ុនភតិសន្យា ក្រុមហ៊ុនផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនគ្រប់គ្រងការវិនិយោគជាដើម។ អាជីវកម្មផ្សេងទៀតរបស់លោកមានដូចជា ក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ ក្រុមហ៊ុនដាំដុះចំការកៅស៊ូ និងចំការស្វាយចន្ទី ។ ភាពជោគជ័យរបស់ក្រុមហ៊ុនក៏ដូចជាការគាំទ្រ ទាំងឡាយពីដៃគូពាណិជ្ជកម្ម និងសាធារណៈជនបានមកពីភាពសុច្ចរិត ស្មោះត្រង់ តម្លាភាព និងការអនុវត្តដោយប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ជាចម្បងរបស់ក្រុមហ៊ុន លី ហួរ គ្រុប។

ក្រុមហ៊ុន លី ហួរ គ្រុប បាននឹងកំពុងចូលរួមចែករំលែកនៅក្នុងភាពរីកចម្រើននៃវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា តាមរយៈក្រុមហ៊ុនចម្រុះដ៏ធំរបស់ខ្លួន។ ជាក់ស្តែង អ្នកឧកញ៉ា លី ហួរ បានទទួលនូវពានរង្វាន់មេដាយ និងការទទួលស្គាល់ជាច្រើនចំពោះការចូលរួមចំណែករបស់លោកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។





## លោក Makoto Miyazaki

### សមាជិកក្រុមប្រឹក្សាភិបាល

លោក Makoto Miyazaki មានបទពិសោធន៍ជាងម្ភៃឆ្នាំក្នុងការដឹកនាំគ្រប់គ្រងជាន់ខ្ពស់នៅក្រុមហ៊ុន SBI Holdings Inc. និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនដ៏ធំនេះ ហើយសព្វថ្ងៃនេះលោកជានាយកប្រតិបត្តិមួយរូបនៃក្រុមហ៊ុន SBI Holdings Inc. ដោយលោកមានតួនាទីដឹកនាំនាយកដ្ឋានគ្រប់គ្រង ពាណិជ្ជកម្មក្រៅប្រទេស។ លោកក៏កាន់តួនាទីធំៗមួយចំនួនទៀតដែរដូចជា អភិបាល អភិបាលមិនប្រតិបត្តិ ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននៃក្រុមហ៊ុនធំៗផ្សេងៗទៀតដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន SBI Holdings Inc.។ លោក Miyazaki មានតួនាទីជាអភិបាលនៅតាមបណ្តាក្រុមហ៊ុនសម្ព័ន្ធ និងក្រុមហ៊ុនវិនិយោគផលប័ត្រជាច្រើនទៀត។ លោក Miyazaki បានចាប់ផ្តើមអាជីពការងារដំបូងរបស់គាត់ជាមួយក្រុមហ៊ុន SBI Holdings Inc. ជានាយកប្រតិបត្តិប្រចាំការិយាល័យតំណាងទីក្រុងប៉េកាំងកាលពីឆ្នាំ២០០៥រហូតដល់ឆ្នាំ២០១២ ។ បន្ទាប់មកលោកក៏ត្រូវបានតែងតាំងជានាយកប្រតិបត្តិដឹកនាំនាយកដ្ឋានគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេសរហូតមកដល់សព្វថ្ងៃនេះ។ នាយកដ្ឋានគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេស គឺជានាយកដ្ឋានដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍរបស់បណ្តាក្រុមហ៊ុនសម្ព័ន្ធទាំងឡាយដែលមាន អាជីវកម្មចម្រុះ មានតាំងពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនបណ្តាក់ទុនសាជីវកម្ម និងក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មជាដើម ដែលមានទីតាំងនៅក្រៅប្រទេសជប៉ុន រួមមាន ប្រទេសអាល្លឺម៉ង់ ហុងកុង ម៉ាឡេស៊ី សាធារណរដ្ឋប្រជាមានិតចិន សិង្ហបុរី កូរ៉េខាងត្បូង ថៃ សហរដ្ឋអាមេរិក និងប្រទេសវៀតណាម។ លោក Miyazaki គឺជាអតីតនិស្សិតនៃសាកលវិទ្យាល័យ Western Oregon University នៃសហរដ្ឋអាមេរិក (ពីមុនត្រូវបានគេស្គាល់ជា Western Oregon State College) ជាកន្លែងដែលលោកបានទទួលបរិញ្ញាបត្រផ្នែកធុរៈកិច្ចរបស់លោក។

## ឧកញ៉ា លី សុភ័ក្ត

### សមាជិកក្រុមប្រឹក្សាភិបាល

ឧកញ៉ា លី សុភ័ក្ត កើតនៅឆ្នាំ១៩៧៨ មានទីកន្លែងកំណើតនៅខេត្តកំពង់ចាម។

ឧកញ៉ា លី សុភ័ក្ត ជាពាណិជ្ជករដែលមានភាពស្វាហាប់ និងមានភាពទាក់ទាញ ជាមួយនឹងបទពិសោធន៍ជាង១០ឆ្នាំ ក្នុងវិស័យពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា។ គាត់បានពង្រីកអាជីវកម្មរបស់គាត់ជាច្រើនមុខតាមរយៈការបណ្តាក់ទុនក្នុងវិស័យផ្សេងៗជាច្រើន ជាពិសេសគឺវិស័យសំណង់ និងវិស័យហិរញ្ញវត្ថុជាដើម ។ គាត់បានចូលរួមចំណែកយ៉ាងច្រើនក្នុងការពង្រឹងវិស័យឯកជន តាមរយៈការជួយឲ្យការវិនិយោគក្នុងស្រុកមានការរីកចម្រើន និងរឹងមាំ។

ឧកញ៉ា លី សុភ័ក្ត ត្រូវបានតែងតាំងជាអនុប្រធានក្រុមហ៊ុន លី ហួរ គ្រុប ក្នុងឆ្នាំ២០០៤ ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិុលស៊ី តាំងពីឆ្នាំ២០១២ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន លី ហួរ លីស៊ីង ភីអិលស៊ី តាំងពីឆ្នាំ២០១៥។





## លោក Shuzo Shikata

### សមាជិកក្រុមប្រឹក្សាភិបាល

លោក Shuzo Shikata ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងជាអភិបាលប្រតិបត្តិរបស់ធនាគារ អេស ប៊ី អាយ លី ហ្ស។ លោកក៏ជាអ្នកតំណាងភាគទុនិករបស់ក្រុមហ៊ុន SBI Holdings Inc. ដែលមានអាសយដ្ឋាននៅទីក្រុងតូក្យូប្រទេសជប៉ុន។ សព្វថ្ងៃនេះ លោកកំពុងបម្រើការងារជាអនុប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ Tien Phong Commercial Bank នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។ លោក Shikata ធ្លាប់ធ្វើការនៅធនាគារដ៏ធំមួយឈ្មោះ ធនាគារ MUFG នៅទីក្រុងតូក្យូ ប្រទេសជប៉ុន មុនពេលលោកចូលបម្រើការងារនៅប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ក្នុងនាមជាអ្នកឯកទេសក្នុងវិស័យសាជីវកម្ម និងធនាគារវិនិយោគគាត់បានចូលរួមកាន់តួនាទីសំខាន់ៗ ជាច្រើននៅក្នុងការពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អ និងការគ្រប់គ្រងឲ្យមានតម្លាភាពនៅក្នុងធនាគារ អេស ប៊ី អាយ លី ហ្ស ។ ដោយមានបទពិសោធន៍យ៉ាងច្រើននៅក្នុងការដឹកនាំគ្រប់គ្រងធនាគារ នៅបរទេសខ្លួនលោកផ្ទាល់ ព្រមទាំងក្រុមហ៊ុន SBI Holdings Inc. បាននឹងកំពុងជួយជ្រោមជ្រែងធនាគារ អេស ប៊ី អាយ លី ហ្ស ក្នុងការរៀបចំ និងអនុវត្តនូវយុទ្ធសាស្ត្រសាជីវកម្មរបស់ធនាគារ ។

លោក Shikata បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Ritsumeikan នៃប្រទេសជប៉ុន។

## លោក Eiichiro So

### សមាជិកក្រុមប្រឹក្សាភិបាល

លោក Eiichiro So បានចូលជាសមាជិកក្រុមប្រឹក្សាភិបាលកាលពីខែធ្នូ ឆ្នាំ២០១៩។ លោកបានធ្វើការជាមួយក្រុមហ៊ុន SBI Group អស់រយៈពេលជាង ១៥ឆ្នាំ មកហើយ ហើយសព្វថ្ងៃនេះលោកជា សហនាយកប្រតិបត្តិ ជានាយកប្រតិបត្តិជាន់ខ្ពស់ និងអនុប្រធាននៃក្រុមហ៊ុន SBI Investment Korea Co., Ltd., ដែលជាក្រុមហ៊ុនបណ្តាក់ដើមទុនសាជីវកម្មដែលបានចុះបញ្ជីក្នុងផ្សារភាគហ៊ុននៅទីផ្សារភាគហ៊ុនកូរ៉េ ឈ្មោះ KOSDAQ (Korean Securities Dealers Automated Quotations) ជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន SBI Royal Security Plc. ជាអភិបាលធនាគារ Tien Phong Commercial Joint Stock Bank (នៅប្រទេសវៀតណាម) និងជាអភិបាលនៃក្រុមហ៊ុន SBI Thai Online Securities Co, Ltd (នៅប្រទេសថៃ)។ ជាមួយបទពិសោធន៍ជាង ២០ (ម្ភៃ) ឆ្នាំរបស់លោកនៅក្នុងវិស័យធនាគារវិនិយោគ និងមូលធនឯកជន (private equity) ជាពិសេសបទពិសោធន៍នៅក្នុងទីផ្សារដែលកំពុងមានការរីកចម្រើនខ្លាំង (រួមមាន កូរ៉េខាងត្បូង សិង្ហបុរី វៀតណាម និងកម្ពុជា) ដោយផ្តោតទៅលើវិស័យហិរញ្ញវត្ថុ (មានដូចជា ធនាគារ មូលបត្រ និងមូលធនឯកជន) លោកបានចូលរួមចំណែកយ៉ាងច្រើនទៅក្នុងការអភិវឌ្ឍអាជីវកម្ម និងបច្ចេកទេសគ្រប់គ្រងរបស់ធនាគារ។

ពីមុនមកលោកធ្លាប់ជាអនុប្រធាននៃធនាគារ Sumitomo Mitsui Banking Corporation ជាអភិបាលនៃធនាគារភ្នំពេញពាណិជ្ជ ជាអភិបាលប្រតិបត្តិនៃ ក្រុមហ៊ុន SBI Ven Capital Pte. Ltd (ប្រទេសសិង្ហបុរី) និងជាអភិបាលនៃ ក្រុមហ៊ុន FPT Securities (ប្រទេសវៀតណាម)។

លោកបានបញ្ចប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មកពីសាកលវិទ្យាល័យHitotsubashi ថ្នាក់ក្រោយឧត្តមសិក្សានៃនាយកដ្ឋានយុទ្ធសាស្ត្រសាជីវកម្មអន្តរជាតិ(ប្រទេសជប៉ុន) និងបរិញ្ញាបត្រផ្នែកគណនេយ្យ មហាវិទ្យាល័យពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Chuo(ប្រទេសជប៉ុន)។



## លោក ខែក រ៉ាវី

### ក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក ខែក រ៉ាវី ត្រូវបានតែងតាំងជាអភិបាលឯករាជ្យ នៅក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស ប៊ី អាយ លី ហ្វូរ ម.ក។

បច្ចុប្បន្ននេះ លោកគឺជាមេធាវី និងជាស្ថាបនិកនៃការិយាល័យមេធាវី DBLS Law ហើយក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន RGL Equity (Siemreap) Co. Ltd., ជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Goodland Group (ជាក្រុមហ៊ុនចុះក្នុងបញ្ជីក្នុងផ្សារភាគហ៊ុនរបស់ប្រទេសសិង្ហបុរី)។

លោកគឺជាអតីតអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា នៅចន្លោះឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៤។

លោក ខែក រ៉ាវី ត្រូវបានជ្រើសតាំងឲ្យក្លាយជាប្រធានសហព័ន្ធកីឡាបាល់ទាត់កម្ពុជាផងដែរ។ ក្នុងអំឡុងពេលនោះ លោកក៏បានបំពេញការងារជាសមាជិកគណៈកម្មាធិការបណ្ដឹងឧទ្ធរណ៍របស់ សហព័ន្ធបាល់ទាត់អន្តរជាតិ ហៅកាត់ថា FIFA។

នៅចន្លោះឆ្នាំ ១៩៨៥ ដល់ឆ្នាំ២០១៩ លោក ខែក រ៉ាវី បានកាន់តួនាទីសំខាន់ៗមួយចំនួនដូចជា ជាភាគទុនិក ជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល និងអភិបាលមិនប្រតិបត្តិនៅតាមបណ្ដា ក្រុមហ៊ុនជាច្រើននៅប្រទេសបារាំង ប្រទេសសិង្ហបុរី និងប្រទេសកម្ពុជាផងដែរ។



## លោក កែណែម វីដាណូ

### ក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក កែណែម វីដាណូ កើតនៅប្រទេសកម្ពុជា ប៉ុន្តែបានចាកចេញទៅរស់នៅប្រទេសបារាំង ទីកន្លែងដែលលោកបានចំណាយពេលវេលាប្រហែលពីរទសវត្សរ៍ដើម្បីសិក្សា និងទទួលបាននូវសញ្ញាបត្របីសំខាន់ៗគឺផ្នែកវិទ្យាសាស្ត្រនយោបាយ ផ្នែកសេដ្ឋកិច្ច និងផ្នែកហិរញ្ញវត្ថុ និងធុរកិច្ច។

លោកបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញនៅកំឡុងពាក់កណ្ដាលទសវត្សរ៍ឆ្នាំ៩០ ដោយពាំនាំនូវ មហិច្ឆតាក្នុងការជួយកសាងប្រទេសកម្ពុជា ដោយបានចូលបម្រើការងារប៉ុន្មានឆ្នាំដំបូងជាមួយក្រុមហ៊ុនសវនកម្មអន្តរជាតិ ហើយក្រោយមកលោកបានចំណាយពេលវេលាប្រហែល ២០ (ម្ភៃ) ឆ្នាំដោយកាន់តួនាទីនាយកប្រតិបត្តិផ្សេងៗដូចជា រដ្ឋលេខាធិការ អគ្គនាយកនៃនាយកដ្ឋានហិរញ្ញវត្ថុ អគ្គនាយកសង្វាក់ផ្គត់ផ្គង់ និងផលិតកម្មនៅក្នុងគម្រោងអភិវឌ្ឍន៍ដែលឧបត្ថម្ភដោយសហភាពអឺរ៉ុបដើម្បីជួយដល់អាជីវកម្មបែបសង្គមកិច្ចដែលបានផ្ដល់ការងារដល់ពលរដ្ឋកម្ពុជាប្រមាណជិត ១២០០ នាក់ ព្រមទាំងថ្នាក់ដឹកនាំផ្សេងៗទៀតដែលស្ថិតនៅក្នុងវិស័យនោះ។

# គណៈគ្រប់គ្រងជាន់ខ្ពស់



## លោក អ៊ុត សឿង

### អគ្គនាយក

លោក អ៊ុត សឿង មកពីខេត្តកំពង់ធំ។ លោកបានចំណាយពេលជាង ១០ឆ្នាំ ធ្វើការនៅក្នុងមុខងារគ្រប់គ្រងជាន់ខ្ពស់ធំៗមួយចំនួននៅក្នុងធនាគារពាណិជ្ជ និងវិស័យមីក្រូហិរញ្ញវត្ថុ ដូចជា៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ ប្រាសាក់ និងធនាគារ ANZ ប្រចាំប្រទេសកម្ពុជា។ លោកមានជំនាញច្បាស់លាស់លើការគ្រប់គ្រងភិតិសន្យា ការផ្តល់ឥណទានសាជីវកម្ម ការគ្រប់គ្រងផលប័ត្រ ការគ្រប់គ្រងឥណទាន ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា។ ក្នុងអំឡុងពេលធ្វើការមួយធនាគារ ANZ លោកបានឈ្នះពានរង្វាន់ផ្នែកអាជីវកម្មលេខ១ ក្នុងឆ្នាំ២០០៩ ជាពេលដែលមានវិបត្តិសេដ្ឋកិច្ច ហើយរហូតមកដល់ចុងឆ្នាំ២០១០ លោកក៏ទទួលបានសិទ្ធិអនុម័ត (CAD) រហូតដល់២លានដុល្លារ ក្នុងពេលដែលលោកជាអ្នកគ្រប់គ្រងហានិភ័យឥណទាន។

ចុងក្រោយ លោកបានដឹកនាំប្រកបដោយភាពជោគជ័យនូវគម្រោង អេ ធី អឹម និងធនាគារចល័តជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករលើមីតធីតដោយប្រើបច្ចេកវិទ្យាថ្មីបំផុត។ ត្រឹមតែរយៈពេល ១២ខែ ក្រោមការដឹកនាំរបស់លោក បានដឹកនាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី ក្លាយជាស្ថាប័នឈានមុខគេមួយក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង១០នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លោកបានចូលរួមផ្តួចផ្តើមគម្រោងពីរ ធំៗគឺ ក្រុមហ៊ុន លី ហួរ លីស៊ីង និង លី ហួរ ផេប្រ៉ូ ភីអិលស៊ី ដែលបានដំណើរការជាផ្លូវការ និងទទួលស្គាល់ពីសាធារណជនយ៉ាងឆាប់រហ័ស ។ កាន់តែពិសេសជាងនេះទៅទៀត លោកគឺជាអ្នកដឹកនាំក្រុមការងារពិសេសក្នុងការកម្លាយខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី ទៅជាធនាគារពាណិជ្ជ។

លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុដែលទទួលបានពីសាលាបារាំងនៅប្រទេសវៀតណាម (CFVG) ក្នុងឆ្នាំ២០០២ ហើយបច្ចុប្បន្នលោកកំពុងតែបន្តការសិក្សាពីជំនាញវិភាគហិរញ្ញវត្ថុ (CFA) ផងដែរ។



## លោក ម៉ៅ ប៉ូឡូ
### អគ្គនាយករង

លោក ម៉ៅ ប៉ូឡូ មកពីខេត្តកណ្តាល។ លោកមានបទពិសោធន៍ជិត ២០ឆ្នាំ ក្នុងការគ្រប់គ្រងរដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ និងការគ្រប់គ្រងផលប័ត្រឥណទាន ទាំងនៅក្នុងអង្គការអន្តរជាតិធំៗ និងគ្រឹះស្ថានធនាគារ ដូចជាធនាគារ ANZ Royal ជាដើម។ ក្នុងអាជីពការងារជាមួយធនាគារ ANZ Royal លោកធ្លាប់ធ្វើជាប្រធានគ្រប់គ្រងហានិភ័យឥណទាន ដែលមានសិទ្ធិអនុម័តសំណើឥណទានរបស់អតិថិជនក្នុងមួយនាក់រហូតដល់ទៅទឹកប្រាក់២លាន ដុល្លារអាមេរិក មុនពេលដែលគាត់ត្រូវបានតំឡើងឋានៈជានាយកឥណទានបុគ្គល ដែលគ្រប់គ្រងឥណទានគេហដ្ឋាន និងឥណទានអាជីវកម្មខ្នាតតូច-មធ្យមរបស់ធនាគារទាំងមូលក្នុងប្រទេសកម្ពុជា។

លោកគឺជានិស្សិតអាហារូបករណ៍ដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុក្នុងឆ្នាំ១៩៩៩ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ បន្ទាប់មកនៅឆ្នាំ២០០៤ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងទូទៅពីសាកលវិទ្យាល័យប្រេសស្តុន សហរដ្ឋអាមេរិក (ជាមហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងគ្រប់គ្រងរដ្ឋបាល) ដែលទទួលស្គាល់ដោយរដ្ឋ Wyoming សហរដ្ឋអាមេរិក។



## លោក ឡុយ សារ៉េត, ACMA, CGMA

### នាយកប្រតិបត្តិ អាជីវកម្ម

លោក ឡុយ សារ៉េត មកពីខេត្តបាត់ដំបង។ លោកមានបទពិសោធន៍ជាង ១៥ ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ មុនពេលចូលបម្រើការងារជាថ្មីនៅធនាគារ អេស ប៊ី អាយ លី ហួរ ម.ក លោក ឡុយ សារ៉េត ធ្លាប់បម្រើការជានាយកប្រតិបត្តិជាន់ខ្ពស់នៅតាមបណ្តាលគ្រឹះស្ថាន និងធនាគារជាច្រើនដូចជា៖ ធនាគារប្រៃសណីយ៍កម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ធនាគារ ANZ រ៉ូយ៉ាល់ និងអង្គការ UNDP។

បច្ចុប្បន្ន លោក ឡុយ សារ៉េត កំពុងសិក្សាលើជំនាញ Chartered Banker (CB) កម្រិត ៣ ពីវិទ្យាស្ថាន Chartered Banker និង Asian Institute of Chartered Banker(AICB)។ លោកជាសមាជិកវិទ្យាស្ថានគណនេយ្យករគ្រប់គ្រងជំនាញ(CIMA) និងបានបញ្ចប់ កំរិតគណនេយ្យករជំនាញសកល (CGMA) ពីចក្រភពអង់គ្លេស។ លោក ឡុយ សារ៉េត ក៏ជាសមាជិករបស់វិទ្យាស្ថានគណនេយ្យករគ្រប់គ្រងជំនាញ និងបានបញ្ចប់កំរិត AMA ពីប្រទេសអូស្ត្រាលី។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យពីសាកលវិទ្យាល័យវេទមហាឫស្សី និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។



## លោក ផាត់ រតនា

### នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង

លោក ផាត់ រតនា មកពីខេត្តសៀមរាប។ លោកមានបទពិសោធន៍ជាង ២០ឆ្នាំ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុក្នុងមុខតំណែងជាច្រើន ដូចជាសវនករផ្ទៃក្នុង បន្ទាប់មកលោកត្រូវបានតែងតាំងជានាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅក្នុងឆ្នាំ១៩៩៩ និងត្រូវបានតែងតាំងជានាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមនៅឆ្នាំ២០១០។ លោកបានសម្រេចនូវសមិទ្ធិផលដ៏ល្អជាច្រើនក្នុងការបំពេញភារកិច្ចដូចជា ការបង្កើតឲ្យមានជាតួនាទី និងដំណើរការប្រតិបត្តិសវនកម្មផ្ទៃក្នុង និងគ្រប់គ្រងហានិភ័យនៅក្នុងស្ថាប័ន។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបានទទួលបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្មជំនាញហិរញ្ញវត្ថុនៅសាកលវិទ្យាល័យ Charles Stuart នៃប្រទេសអូស្ត្រាលី។



## លោក លន់ លាងអេង

### នាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក លន់ លាងអេង មកពីរាជធានីភ្នំពេញ។ លោកមានបទពិសោធន៍ ១០ ឆ្នាំក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំផែនការថវិកា និងការព្យាករហិរញ្ញវត្ថុនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។ ក្នុងកំឡុងពេលធ្វើការនៅអម្រឹត លោកបានបង្កើតមុខងារគ្រប់គ្រងផ្នែករតនាភិបាល ការគ្រប់គ្រងទ្រព្យសម្បត្តិសកម្ម និងទ្រព្យអសកម្ម ការរៀបចំផែនការសាច់ប្រាក់ គម្រោងថវិកាជាមួយអ្នកផ្តល់ប្រាក់កម្ចីក្នុងស្រុក និងក្រៅស្រុក និងការរៀបចំវិភាគរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំជាដើម។ លើសពីនេះទៀត លោកក៏បានចូលរួមជាមួយសមាជិកនៃគណៈកម្មការកម្ចី គណកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម (ALCO) កម្មវិធីបុគ្គលិកប្រសិទ្ធិការងារខ្ពស់ ក្រុមការងារអភិវឌ្ឍន៍ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ក្រុមការងារកិច្ចព្រមព្រៀងកម្រិតសេវា (SLA)ក្រុមអនុគណៈកម្មការផ្តល់ប្រឹក្សាអំពីហានិភ័យហិរញ្ញវត្ថុ អនុគណៈកម្មការអាជីវកម្មសហគមន៍ និងក្រុមកែលម្អដំណើរការ (Kaizen)។ មុនពេលធ្វើការឲ្យ អម្រឹត លោកមានបទពិសោធន៍ការងារផ្នែកគណនេយ្យ និងហិរញ្ញវត្ថុចំនួន ៨ ឆ្នាំជាមួយក្រុមហ៊ុនក្នុងស្រុកនិងអន្តរជាតិផងដែរ។

លោកបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ ២០០៨ និងទទួលបានបរិញ្ញាបត្រគណនេយ្យពីវិទ្យាស្ថានជាតិគ្រប់គ្រងក្នុងឆ្នាំ ២០០២ ផងដែរ។



## លោក ចាប ចំណាប់

### នាយកប្រតិបត្តិព័ត៌មានវិទ្យា

លោក ចាប ចំណាប់ មកពីទីក្រុងភ្នំពេញ ។ លោកមានបទពិសោធន៍ជាង១៥ឆ្នាំទៅលើផ្នែកព័ត៌មានវិទ្យានៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ ជាមួយនឹងបទពិសោធន៍ជាច្រើនឆ្នាំ លោកបានឆ្លងកាត់ និងកាន់កិច្ចការងារដូចជាហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា ផលិតកម្មវិធីកុំព្យូទ័រ គ្រប់គ្រងគម្រោងព័ត៌មានវិទ្យាប្រព័ន្ធធនាគារស្នូល និងប្រព័ន្ធធនាគារចល័ត។ ចំណុចកត់សម្គាល់របស់លោក គឺ ការគ្រប់គ្រងគម្រោងព័ត៌មានវិទ្យា និងភាពជាអ្នកដឹកនាំ។

លោក ចាប ចំណាប់ បានបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យាពីសកលវិទ្យាល័យន័រតុន និងបរិញ្ញាប័ត្រចំនួនពីរផ្សេងទៀតលើផ្នែកគណនេយ្យ និងផ្នែកព័ត៌មានវិទ្យាផងដែរ។



## លោក អាំង ប៊ុនសេង

### នាយកប្រតិបត្តិធនធានមនុស្ស

លោក ប៊ុនសេង មានបទពិសោធន៍ច្រើនជាង១៥ឆ្នាំជាមួយវិស័យហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មុនពេលចូលរួមជាមួយ ធនាគារ អេស ប៊ី អាយ លី ហួរ លោកធ្លាប់កាន់តំណែងជាអ្នកដឹកនាំជាន់ខ្ពស់ផ្នែកគ្រប់គ្រងធនធានមនុស្សនៅស្ថាប័នជាច្រើនដូចជា៖ ធនាគារ ស្ថាបនា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ធនាគារ អេ អ៊ិន ហ្ស៊ី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ និងប្រាសាក់។

លោក ប៊ុនសេង បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម ពីវិទ្យាស្ថានសម្រាប់ការអបរំពាណិជ្ជកម្ម នៅក្នុងឆ្នាំ២០០៩ និងបរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រងក្នុងឆ្នាំ២០០៤។



## លោក រស់ សុខា

### ទីប្រឹក្សាជាន់ខ្ពស់ធនាគារឌីជីថល ប្រតិបត្តិការធនាគារ និងបច្ចេកវិទ្យា

លោក រស់ សុខា មានបទពិសោធន៍ជាង២០ឆ្នាំក្នុងវិស័យធនាគារ។ លោកបានចាប់ផ្តើមអាជីពជាមួយវិស័យធនាគារដំបូងជាធនាគារ UCB ដោយធ្វើការគ្រប់គ្រងមជ្ឈមណ្ឌលកាតអេឡិចត្រូនិចតាមរយៈក្នុងអនុវត្តន៍ប្រព័ន្ធEMV(Europay, MasterCard and Visa)។ លោកបានចូលរួមជាមួយធនាគារ ANZ ក្នុងឆ្នាំ២០០៥ដោយធ្វើការសហប្រតិបត្តិការជាមួយក្រុមការងារគំរោងប្រចាំតំបន់ដើម្បីដំណើរការប្រព័ន្ធធនាគារអេឡិចត្រូនិចសម្រាប់តំបន់ទាំងមូលដោយធ្វើការបំលែង និងទំនើបកម្មវិស័យធនាគារ។ លោកក៏បានចូលក្នុងការជម្រុញការបំលែងខ្លួនក្នុងការប្រើប្រាស់ប្រព័ន្ធធនាគារ និងកាតអេឡិចត្រូនិច របស់ធនាគារ ANZ ក្នុងប្រទេសឡាវផងដែរ។ លោកក៏បានចូលរួមជាមួយធនាគារ FTB ក្នុងការដឹកនាំកាតអេឡិចត្រូនិច និងធនាគារឌីជីថល មុនពេលលោកចូលរួមជាមួយធនាគារស្ថាបនា មានតួនាទីជា នាយកប្រតិបត្តិឌីជីថល ក្នុងការដឹកនាំដំណាក់កាលធ្វើការបំលែងខ្លួនទៅជាធនាគារឌីជីថល។

លោក រស់ សុខា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីវិទ្យាស្ថានបច្ចេកទេសអាស៊ានប្រទេសថៃ និងAudencia Business School ប្រទេសបារាំង នៅឆ្នាំ១៩៩៩។



## ឧកញ៉ា លី សុភាព

### នាយករងប្រតិបត្តិ ប្រតិបត្តិការ

ឧកញ៉ា លី សុភាព មកពីខេត្តកំពង់ចាម។ លោកមានបទពិសោធន៍យ៉ាងច្រើនក្នុងតំណែងជាអ្នកដឹកនាំជាន់ខ្ពស់ដូចជា ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន លី ហួរ ផេរលុយចាប់ពីឆ្នាំ២០១៦។ក្នុងអំឡុងពេលជាមួយគ្នានោះដែរលោកក៏ត្រូវបានតែងតាំងជាអគ្គនាយកក្រុមហ៊ុន លី ហួរ អ៊ិច ឆេង និងគ្រឿងអលង្ការ (រតនៈអលង្ការ)ផងដែរ។ លោកក៏គ្រប់គ្រងអាជីវកម្មមួយចំនួនដូចជា ក្រុមហ៊ុន IKVM Distribution Co., Ltd., ក្រុមហ៊ុនដឹកជញ្ជូនចំណីអាហារ, ក្រុមហ៊ុន IG Consultant Co., Ltd., និងក្រុមហ៊ុនជ្រើសរើសធនធានមនុស្ស។

ឧកញ៉ា លី សុភាព ទទួលបានវិញ្ញាបនបត្រគណនេយ្យក្នុងឆ្នាំ១៩៩៩ ពីប្រទេសសិង្ហបុរី។ លោកក៏ទទួលបានបរិញ្ញាបត្រកិត្តិយសផ្នែករចនាពហុប្រព័ន្ធផ្សព្វផ្សាយពីសាកលវិទ្យាល័យ Huddersfield ទីក្រុង Manchester របស់ចក្រភពអង់គ្លេសនៅក្នុងឆ្នាំ២០០៤ ផងដែរ។



## លោក អាំង សុវណ្ណារ៉ា

### នាយករងប្រតិបត្តិហានិភ័យ

លោក អាំង សុវណ្ណារ៉ា មកពីទីក្រុងភ្នំពេញ។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ ដោយធ្លាប់ទទួលបន្ទុកលើមុខងារជាច្រើនដូចជាហានិភ័យ ប្រតិបត្តិតាម ផ្នែកប្រតិបត្តិការ និងបទពិសោធន៍អតិថិជន។ តួនាទីចុងក្រោយរបស់លោកគឺដឹកនាំផ្នែកហានិភ័យនិងប្រតិបត្តិតាមនៅក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA។ លោកក៏ធ្លាប់កាន់តួនាទីជានាយកនាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម នៅធនាគារ Hong Leong បន្ទាប់ពីទទួលបានជោគជ័យក្នុងការដឹកនាំប្រតិបត្តិការសាខា យុទ្ធសាស្រ្តធនាគារ នីតិវិធី និងវិធីសាស្រ្ត តាំងពីឆ្នាំ២០១៣។ក្នុងអាជីពដំបូងរបស់លោក លោកធ្លាប់ធ្វើការដឹកនាំគម្រោងស្រាវជ្រាវសេដ្ឋកិច្ចរបស់ធនាគារពិភពលោក និងគម្រោងជាច្រើនទៀតជាមួយស្ថាប័នអន្តរជាតិនានា។ បន្ទាប់មកទៀតលោកក៏បានចូលរួមជាមួយក្រុមហ៊ុន Cellcard ដែលជាក្រុមហ៊ុនទូរគមនាគមន៍ឈានមុខគេនៅកម្ពុជា ដោយមានតួនាទីជាអ្នកដឹកនាំកម្មវិធីថែរក្សាអតិថិជន និងការស្រាវជ្រាវ។

លោក អាំង សុវណ្ណារ៉ា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួនបីផ្សេងគ្នា គឺបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិស្វកម្មហេដ្ឋារចនាសម្ព័ន្ធពីសាកលវិទ្យាល័យ Gembloux Agro-Bio Tech ប្រទេសបែលហ្ស៊ិកក្នុងឆ្នាំ២០០៥ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៧ និងបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអន្តរជាតិ ពីសាកលវិទ្យាល័យ Audencia Business School ប្រទេសបារាំង ក្នុងឆ្នាំ២០០៧។

# រចនាសម្ព័ន្ធគណៈគ្រប់គ្រង




អ្នកស្រី សុខ សោភ័ណ
ជំនួយការប្រធានក្រុមប្រឹក្សាភិបាល

គណៈកម្មការត្រួតពិនិត្យហានិភ័យ


លោក ឡូយ សារ៉េត
នាយកប្រតិបត្តិ អាជីវកម្ម


អ្នកស្រី ម៉ក់ វិទ្ធកល្យាណ
នាយិកា នាយកដ្ឋាន
ធនាគារពាណិជ្ជកម្ម


លោក អ៊ួង អាន
នាយក នាយកដ្ឋានភតិសន្យា


លោក ខៀវ សម្បត្តិធនធាន
នាយក នាយកដ្ឋានប្រាក់បញ្ញើ


អ្នកស្រី ចាន់ ចិន្តា
នាយិកា នាយកដ្ឋាន
ទូទាត់អន្តរជាតិ


លោក លន់ លាងអេង
នាយកប្រតិបត្តិ ហិរញ្ញវត្ថុ


អ្នកស្រី អឿន សុភ័ក្ត្រណា
នាយិកា នាយកដ្ឋានហិរញ្ញវត្ថុ


លោក ថន វិទូ
នាយក នាយកដ្ឋានរតនាភិបាល


លោក សរ បូរ៉ា
នាយក នាយកដ្ឋានរដ្ឋបាល


លោក Shuzo Shikata
នាយកប្រតិបត្តិតំណាងភាគទុនិក


លោក រស់ សុខា
ទីប្រឹក្សាជាន់ខ្ពស់ផ្នែកសេវាហិរញ្ញវត្ថុ
ឌីជីថល ប្រតិបត្តិការធនាគារ និងបច្ចេកវិទ្យា


លោក ហេង ចាន់វីរដ្ឋា
នាយក នាយកដ្ឋានដៃគូអាជីវកម្ម


លោក សន វីហ៊ួន
នាយក នាយកដ្ឋានលេខាធិការ
ក្រុមហ៊ុន


លោក អាំង សុវណ្ណារ៉ា
នាយករងប្រតិបត្តិហានិភ័យ


លោក ជា សៀងលី
នាយក នាយកដ្ឋានហានិភ័យ
ឥណទាន


លោក កេន ម៉ាឡែន
នាយក នាយកដ្ឋានសេវាកម្ម
ឥណទាន


លោក ស៊ឹម គីមសេង
នាយក នាយកដ្ឋានហានិភ័យ
និងប្រតិបត្តិតាម

# ការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យ ជាកត្តាចំបងដែលធនាគារ អេស ប៊ី អាយ លី ហួរ ម.ក បាន នឹងកំពុងយកចិត្តទុកដាក់ខ្លាំងពីព្រោះវាជាកម្លាំងចលករមួយ ដែលអាចនាំអោយ ធនាគារទាំងមូលឈានទៅរកភាពជោគជ័យ និងរក្សានូវនិរន្តរភាពយូរអង្វែង។ ទន្ទឹមនឹងគ្នានេះ ដើម្បីធ្វើឲ្យការគ្រប់គ្រងហានិភ័យមានប្រសិទ្ធភាព ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក បានប្រកាន់យកគោលការណ៍អាទិភាពមួយគឺ ទប់ស្កាត់ ជាមុននូវរាល់ហានិភ័យទាំងឡាយណាដែលអាចកើតមានឡើងចំពោះធនាគារ ។

ជាលក្ខណៈបច្ចេកទេស ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រងហានិភ័យរបស់ ធនាគារទាំងមូលឲ្យបានល្អ និងមានប្រសិទ្ធភាព ធនាគារបានកំណត់នូវវិធានការ និងបែងចែកការទទួលខុសត្រូវអោយបានច្បាស់លាស់ ដាច់ដោយឡែកជាបីផ្នែក ផ្សេងៗគ្នាដូចខាងក្រោម៖

(១)ផ្នែកប្រតិបត្តិការ៖ កម្រិតទី១នៃការត្រួតពិនិត្យហានិភ័យគឺមានការត្រួតពិនិត្យ ស្វ័យប្រវត្តិទៅតាមកំរិតឋានានុក្រមនៅក្នុងអាជីវកម្មផ្ទាល់។



(២)ផ្នែកហានិភ័យ៖ កម្រិតទី២នៃការត្រួតពិនិត្យតាមរយៈអ្នកត្រួតពិនិត្យតំបន់ ប្រតិបត្តិការ និងអ្នកវិភាគហានិភ័យដែលធ្វើឡើងដោយ នាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាមរបស់ធនាគារ។

(៣)ផ្នែកសវនកម្មផ្ទៃក្នុង៖ កម្រិតទី៣គឺធ្វើឡើងជាប្រចាំដោយអាណត្តិរបស់នាយក ដ្ឋានសវនកម្មផ្ទៃក្នុង។

ទាំងនេះគូសបញ្ជាក់អោយឃើញថារាល់ការអនុវត្តការងាររបស់ផ្នែកនីមួយៗគឺប្រកប ដោយភាពឯករាជ្យម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់។ នាពេលបច្ចុប្បន្នធនាគារ ក៏បានរៀបចំបង្កើតនូវគោលនយោបាយគ្រប់គ្រងហានិភ័យមួយចំនួនផងដែរ ដូចជាគោលនយោបាយហានិភ័យប្រតិបត្តិការ ហានិភ័យហិរញ្ញវត្ថុ និងហានិភ័យ ឥណទានជាដើម ដើម្បីគាំទ្រដល់ការអនុវត្តការងាររបស់បុគ្គលិក។

បន្ថែមពីលើនេះទៀត ដើម្បីឲ្យការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធ និង មានភាពងាយស្រួលដល់គណៈគ្រប់គ្រងក្នុងការតាមដាន និងស្វែងរកមធ្យោបាយ ដោះស្រាយ ធនាគារក៏បានកំណត់នូវដំណើរការ ៤យ៉ាង មកប្រើប្រាស់រួមមាន ការកំណត់ហានិភ័យ ការវាយតម្លៃពីហានិភ័យ ការគ្រប់គ្រងហានិភ័យ និងការ ត្រួតពិនិត្យហានិភ័យ។ នាយកដ្ឋានហានិភ័យមានតួនាទីសំខាន់ក្នុងការកំណត់ ហានិភ័យដែលពាក់ព័ន្ធជាមួយនឹងការអនុវត្តការងាររបស់បុគ្គលិក និងនីតិវិធីនានា របស់នាយកដ្ឋាននីមួយៗ បន្ទាប់ពីហានិភ័យត្រូវបានកំណត់នោះ វានឹងត្រូវបាន វាយតម្លៃជាពិសេស អំពីលទ្ធភាពដែលអាចកើតមានឡើង ព្រមទាំងផលប៉ះពាល់ ចំពោះគ្រឹះស្ថាន។ មធ្យោបាយនានាក៏ត្រូវបានប្រើប្រាស់ដូចជាការកត់ត្រាទៅក្នុង បញ្ជីហានិភ័យ ជាមួយនឹងចំណាត់ថ្នាក់របស់វាផងដែរ។ ធនាគារនឹងកំណត់ យកយុទ្ធសាស្ត្រដ៏សមស្របដើម្បីដោះស្រាយ និងកាត់បន្ថយនូវកម្រិតហានិភ័យ ដែលប្រឈមទាំងនោះដូចជាការទទួលយកការដោះស្រាយ ការផ្ទេរ និងការបញ្ចៀស នូវហានិភ័យទាំងនោះជាដើម។ បន្ទាប់មកទៀតធនាគារនឹងបន្តធ្វើការត្រួតពិនិត្យ ជាប្រចាំដើម្បីប្រាកដថាហានិភ័យទាំងនោះត្រូវបានគ្រប់គ្រង និងដោះស្រាយយ៉ាង សមស្រប ឬផែនការសកម្មភាពថ្មីគួរត្រូវបានបង្កើតឡើងដើម្បីប្រើប្រាស់ និងកាត់ បន្ថយកម្រិតប្រឈមខ្ពស់ ដែលនៅមិនទាន់ដោះស្រាយនៅឡើយ។




ចុងក្រោយ ឥណទានហានិភ័យ គឺជាហានិភ័យមួយដែលមានសក្តានុពលជាខ្លាំងក្នុងចំណោមហានិភ័យដទៃទៀតដែលវាអាចជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់ដំណើរការរបស់ស្ថាប័នក្នុងប្រតិបត្តិការរយៈពេលវែងហើយវាក៏អាចរាំងស្ថាប័ននៅក្នុងការឈានទៅរកការសម្រេចផែនការកំណើនអាជីវកម្មផងដែរ។ ដូច្នេះដើម្បីធ្វើឲ្យប្រាកដថាស្ថាប័នដំណើរការដោយរលូន និងគ្រប់គ្រងបានល្អនូវហានិភ័យបែបនេះក្នុងប្រតិបត្តិការរយៈពេលវែង គណៈកម្មការគ្រប់គ្រងហានិភ័យដោយមានការជួយគាំទ្រយ៉ាងខ្លាំងពី គណៈកម្មការក្រុមប្រឹក្សាភិបាលគ្រប់គ្រងហានិភ័យក៏បានយកចិត្តទុកដាក់ទៅលើបញ្ហានៃហានិភ័យប្រភេទនេះផងដែរ។តាមលក្ខណៈបច្ចេកទេសការកំណត់នូវកម្រិតលក្ខខណ្ឌហានិភ័យ គឺត្រូវបានកំណត់យ៉ាងច្បាស់សម្រាប់ស្ថាប័ន ជាពិសេសអំពីកត្តាមួយចំនួនដូចជា កម្រិតចំនួន ផលិតផល និងលក្ខណៈវិនិច្ឆ័យផលិតផលនិងលក្ខណៈពិសេសផ្សេងៗរបស់ផលិតផលនោះដើម្បីឲ្យបុគ្គលិកទាំងអស់មានភាពច្បាស់លាស់ និងងាយស្រួលក្នុងការអនុវត្ត។ លើសពីនេះទៅទៀតនោះលក្ខខណ្ឌទាំងអស់នេះក៏ត្រូវបានត្រួតពិនិត្យឡើងវិញ និងកែលម្អជាប្រចាំដើម្បីធានាថាអ្វីដែលបានកំណត់គឺនៅតែឆ្លុះបញ្ចាំងពីកាលៈទេសៈជាក់ស្តែងនៃស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

# ធនធានមនុស្ស

ធនាគារ អេស ប៊ី អាយ លីហ្សូ ម.ក គឺជាធនាគារពាណិជ្ជកម្មដែលបានវិវឌ្ឍខ្លួនថ្មី ក្នុងអំឡុងពេលដែលស្ថាប័នហិរញ្ញវត្ថុទាំងអស់ក្នុងសកលលោកជួបបញ្ហាប្រឈមជាមួយនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។ធនាគាររបស់យើងផ្តោតលើការអនុវត្តវប្បធម៌ដោយផ្អែកលើលទ្ធផល គុណភាព និងបន្តការកែលម្អការងារជាប្រចាំ។ យើងឲ្យតម្លៃទៅលើភាពសម្បូរបែបនៃធនធានមនុស្ស និងផ្តល់អោយបុគ្គលិកយើងម្នាក់ៗនូវឱកាសស្មើៗគ្នាក្នុងការបន្តនូវការបំពេញការងារប្រកបដោយទំនួលខុសត្រូវខ្ពស់។ លើសពីនេះ យើងពិតជាមានមោទកភាពដែលមានបុគ្គលិកពោរពេញទៅដោយភាពរីកចម្រើន ក៏ដូចជាមានការលូតលាស់ជាលំដាប់ចាប់ពីតួនាទីថ្នាក់ទាបរហូតទៅដល់អ្នកគ្រប់គ្រងជាន់ខ្ពស់ និងនាយកនាយកដ្ឋានតាំងពីពេលដែលយើងនៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរហូតមកដល់ពេលបច្ចុប្បន្ននេះ។

បុគ្គលិកទាំងអស់របស់ធនាគារ អេស ប៊ី អាយ លី ហ្សូ ម.ក គឺជាទ្រព្យដ៏មានតម្លៃ និងជាសសរទ្រទ្រង់ដ៏រឹងមាំដែលធ្វើឲ្យធនាគារទទួលបានជោគជ័យក្នុងអាជីវកម្មដូចសព្វថ្ងៃនេះ។ ធនាគារឲ្យតម្លៃយ៉ាងខ្ពស់ទៅលើភាពចម្រុះនៃធនធាន និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកដែលមានទេពកោសល្យដើម្បីសម្រេចបាននូវទំនាក់ទំនងល្អប្រសើរ នឹងការផ្តល់ជូននូវផលិតផល និងសេវាកម្មធនាគារប្រកបភាពជោគជ័យចំពោះអតិថិជនទិសដៅដែលមានសក្តានុពល។

នៅចុងខែធ្នូ ឆ្នាំ២០២០ នេះ ចំនួនសរុបបុគ្គលិកនៅក្នុងធនាគារ បានកើនឡើងពីចំនួន៥៩៧ ក្នុងឆ្នាំ២០១៩ រហូតដល់១.១៥៧ (បុគ្គលិកជាស្ត្រីមានចំនួន៣១៤ នាក់)។ ធនាគារបានជ្រើសរើសបុគ្គលិកថ្មីប្រមាណជាង ៧៣០នាក់បន្ថែម។ ភាគច្រើននៃមុខតំណែងដែលត្រូវបានជ្រើសរើស គឺត្រូវបានផ្តោតទៅលើមុខតំណែងជួរមុខដើម្បីជាការបង្កើនចំនួននិយោជិកដែលមានស្រាប់ នឹងយកមកជំនួសតំណែងនិយោជិកដែលបានលាឈប់។

អគ្គនាយកដ្ឋានធនធានមនុស្សផ្តោតលើការកែសម្រួលដំណើរការគ្រប់គ្រងធនធានមនុស្សឲ្យមាន ភាពប្រសើរឡើងវិញ គុណភាពនៃការផ្តល់សេវាកម្ម ការរៀបជាយុទ្ធសាស្ត្រនូវផែនការនិងការអភិវឌ្ឍធនធានមនុស្សព្រមទាំងការប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាពខ្ពស់ដើម្បីធានាឲ្យបានជានិរន្តនូវការគាំទ្រប្រតិបត្តិការអាជីវកម្មធនាគារ។

ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលសមត្ថភាពបុគ្គលិកអគ្គនាយកដ្ឋានធនធានមនុស្សផ្តល់នូវឱកាសបណ្តុះបណ្តាល និងអភិវឌ្ឍន៍យ៉ាងសម្បូរបែបក្នុងការគាំទ្ររាល់ដំណាក់កាលនៃភាពរីកចម្រើនរបស់បុគ្គលិកគ្រប់រូបចាប់តាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ តាមរយៈកម្មវិធីបណ្តុះបណ្តាលដ៏ទូលំទូលាយរបស់យើង។វិធីសាស្ត្រអភិវឌ្ឍបុគ្គលិករួមមានការបណ្តុះបណ្តាលដោយរួមបញ្ចូលគ្នាជាមួយនឹងបទពិសោធន៍ការងារជាក់ស្តែង ការរៀនសូត្រតាមរយៈអ្នកដទៃ ព្រមទាំងកម្មវិធីបណ្តុះបណ្តាលជាផ្លូវការ រួមទាំងវគ្គបណ្តុះបណ្តាលនៅឯក្រៅប្រទេសផងដែរ។ នាពេលកន្លងមក យើងបានធ្វើការសម្របសម្រួល និងអនុវត្តកម្មវិធីណែនាំ ការបណ្តុះបណ្តាលផ្ទៃក្នុង ការរៀនសូត្រតាមរយៈប្រព័ន្ធអនឡាញ និងកម្មវិធីអភិវឌ្ឍន៍ជំនាញសំខាន់ៗផ្សេងៗទៀតសម្រាប់បុគ្គលិកយើងចំនួន ២.៩៥៦នាក់ នៅឆ្នាំ២០២០ ។

ការបន្តធ្វើវិនិយោគទុនទៅលើបុគ្គលិកគ្រប់រូបរបស់យើង គឺជាកាតព្វកិច្ចយ៉ាងសំខាន់សម្រាប់យើង។


HR

# អំពីផលិតផល និងសេវាកម្ម

## ប្រាក់កម្ចី

### ឥណទាន ណាណូ
- រយៈពេលកម្ចី : ២៤ ខែ
- អត្រាការប្រាក់ : ១,៤៥% - ១,៥%
- ទំហំឥណទាន : រហូតដល់ ៦លានរៀល
- មិនត្រូវការទ្រព្យធានា
- មានធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល ១ម៉ឺនដុល្លារ

### ឥណទានខ្នាតតូចបំផុត
- រយៈពេលកម្ចី : ៩៦ ខែ
- អត្រាការប្រាក់ : ១,១៨% - ១,៥%
- ទំហំឥណទាន : ៥០០ រហូត ១០.០០០ដុល្លារ (ឬ រូបិយប័ណ្ណសមមូល)

### ឥណទានខ្នាតតូច
- រយៈពេលកម្ចី : ១២០ ខែ
- អត្រាការប្រាក់ : ០,៨៧% - ១,៣%
- ទំហំឥណទាន:  ១០.០០១ - ៥០.០០០ដុល្លារ (ឬ រូបិយប័ណ្ណសមមូល)

### ឥណទានអាជីវកម្មខ្នាតតូច និងមធ្យម
- រយៈពេលកម្ចី : ១២០ ខែ
- អត្រាការប្រាក់ : ០,៧៥% - ១,១០%
- ទំហំឥណទាន : រហូតដល់ ២០ម៉ឺនដុល្លារ (ឬ រូបិយប័ណ្ណសមមូល)

### ឥណទានគេហដ្ឋាន
- រយៈពេល: រហូតដល់ ២០ឆ្នាំ
- ទំហំឥណទាន : ៨០% នៃតម្លៃផ្ទះ

### ឥណទានពាណិជ្ជកម្ម
- រយៈពេល: រហូតដល់ ១២០ខែ
- ទំហំឥណទានធំជាង ២០ម៉ឺនដុល្លារ (ឬ រូបិយប័ណ្ណសមមូល)



## បញ្ញើសន្សំមាន
## កាលកំណត់




- គណនីសន្សំ
- គណនីចរន្ត
- គណនីចរន្តព្រីមៀរ
- គណនីចម្រើនតាមបំណង
- គណនីសន្សំតាមផែនការ

## ប្រាក់សន្សំ





# ០២

## របាយការណ៍ហិរញ្ញវត្ថុ


របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ____ ៣១

របាយការណ៍របស់សវនករឯករាជ្យ ____ ៣៥

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ____ ៣៧

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ ____ ៣៨

របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ____ ៣៩

របាយការណ៍លំហូរទឹកប្រាក់ ____ ៤១

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយ ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក (ពីមុនត្រូវបានគេស្គាល់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី) ហៅកាត់ថា ("ធនាគារ") ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ។

## សកម្មភាពចម្បង

ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក (ពីមុនត្រូវបានគេស្គាល់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី) (ហៅកាត់ថា "ធនាគារ") បានបង្កើតឡើង និង ចុះបញ្ជីជាធនាគារមហាជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០១៣១៣ ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១២ ពីក្រសួងពាណិជ្ជកម្ម ។ នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២ ធនាគារបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

ធនាគារ បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០។

កម្មវត្ថុរបស់ធនាគារ គឺធ្វើការផ្តល់ជូននូវអាជីវកម្មធនាគារពាណិជ្ជទាំងអស់ ដល់រូបវន្តបុគ្គល សហគ្រាសធុនតូច និងមធ្យម ក្រុមហ៊ុន និងសាជីវកម្មទូទៅ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងៗទៀត ដូចដែលបានធ្វើឡើងដោយរាល់ធនាគារពាណិជ្ជអន្តរជាតិទាំងអស់ ។ គោលបំណងរបស់ធនាគារ គឺដើម្បីជួយដល់ប្រទេសកម្ពុជា អាជីវកម្ម និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងការរីកលូតលាស់របស់អាជីវកម្ម ដោយធ្វើការផ្តល់នូវសេវាកម្មធនាគារដែលមានជំនាញវិជ្ជាជីវៈ បច្ចេកវិទ្យាជឿនលឿន ជាមួយនឹងហិរញ្ញប្បទានដែលមានលក្ខៈសមរម្យ ។
ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក មានសកម្មភាពអាជីវកម្មចម្បងៗដូចខាងក្រោម ៖

- ក.ប្រតិបត្តិការនៃសកម្មភាពធនាគារតាមរយៈការផ្តល់សេវាកម្មធនាគារ និង
- ខ.សកម្មភាពអាជីវកម្មផ្សេងទៀត ដែលត្រូវបានចាត់ទុកថាសមស្របចំពោះធនាគារ និងដែលអនុលោមទៅតាម បទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់(ខាត)/ចំណេញមុនដកពន្ធ | (៩៩៥.៥៤៤) | (៤.០៥៨.៨៣២) | ២.៨៨៥.២៩០ | ១១.៦៩១.១៩៥ |
| អត្ថប្រយោជន៍/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ២១៣.១៩៩ | ៨៦៩.២១២ | (៦២០.៩៩២) | (២.៥១៥.៨៥៤) |
| ប្រាក់(ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | (៧៨២.៣៤៥) | (៣.១៨៩.៦២០) | ២.២៦៤.៣៩៨ | ៩.១៧៥.៣៤១ |

## ភាគលាភ

សម្រាប់ការិយបរិច្ឆេទសវនកម្មនេះ ពុំមានការប្រកាស ឬការបែងចែកភាគលាភនោះទេ ហើយក្រុមប្រឹក្សាភិបាល ក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភនោះដែរ ។

## ដើមទុន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទាន និងបុរេប្រទាន

នៅមុនពេលដែល របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបចោលនៃឥណទាននិងបុរេប្រទានអាក្រក់និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់លើការបាត់បង់ឥណទាន និងបុរេប្រទាន ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃឥណទាន និងបុរេប្រទានអាក្រក់ដែលបានលុបចោល ឬចំនួននៃការធ្វើសំវិធានធនលើការបាត់បង់ឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្ម(លើកលែងបំណុល)ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានបន្ថយឲ្យនៅស្មើនឹងតម្លៃដែលអាចរំពឹងថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវ ឬ មិនសមស្របនោះទេ ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមានៈ

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬ បំណុលផ្សេងៗទៀតរបស់ធនាគារ ដែលធនាគារត្រូវបំពេញ ឬ អាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុ នឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ ។

## ការប្រែប្រួលសភាពការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាលរបស់ធនាគារពុំបានពិនិត្យឃើញសភាពការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹង បណ្តាលឲ្យមានតួលេខនៃចំនួនណាមួយនៅក្នុង របាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់គណៈគ្រប់គ្រង លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការពីព្រឹត្តិការណ៍ឬធាតុណាមួយដែលមានលក្ខណៈមិនប្រក្រតីនោះទេ ។ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថានៅក្នុងចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះពុំមាន សកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីដែលទំនងជាអាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទបច្ចុប្បន្នដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ លើកលែងតែការផ្ទុះឡើងនៃ វីរុសណូវែលកូរ៉ូណា ("កូវីដ-១៩") ។

## វីរុសកូរ៉ូណា និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក

ការខាតបង់ឥណទានរំពឹងទុក ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចមួយចំនួនដែលបានព្យាករណ៍ទុក នៅក្នុងការិយបរិច្ឆេទរាយការណ៍ ។ ការផ្ទុះឡើងនៃ វីរុសណូវែលកូរ៉ូណា ("កូវីដ-១៩") បានរាតត្បាតប្រទេសចិនដីគោក ប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ដែលព្រឹត្តិការណ៍បានធ្វើឲ្យមានការរាំងស្ទះសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច ។ ផលប៉ះពាល់ទៅលើផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងសូចនាករសំខាន់ ផ្សេងៗ ត្រូវបានយកមកពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងភវនីយភាពនៃការធ្លាក់ចុះនៃសេដ្ឋកិច្ច ដែលត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណការខាតបង់ឥណទានរំពឹងទុកដោយក្នុងនោះការគណនាលើការខាតបង់ឥណទានរំពឹងទុកនៅស្ថានភាពបច្ចុប្បន្ន អាចមានភាពមិនប្រាកដប្រជាជាសារវន្ត ។ អ្នកគ្រប់គ្រង បានធ្វើការប៉ាន់ប្រមាណ លើលផលប៉ះពាល់ដែលអាចកើតឡើងចំពោះធនាគារពីជំងឺកូវីដ-១៩ ប៉ុន្តែការប៉ាន់ប្រមាណនេះអាចនឹងមានការផ្លាស់ប្តូរជាសារវន្តពេលមានព្រឹត្តិការណ៍ថ្មីកើតឡើង ។

## ក្រុមប្រឹក្សាភិបាល

អភិបាលដែលបានបម្រើការនៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅថ្ងៃដែលចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| អ្នកឧកញ៉ា លី ហួរ | ប្រធានក្រុមប្រឹក្សាភិបាល |
| ឧកញ៉ា លី សុភ័ក្ត្រ | អភិបាល |
| លោក Makoto Miyazaki | អភិបាល |
| លោក Eiichiro So | អភិបាល |
| លោក Shuzo Shikata | អភិបាល |
| លោក Chiang Huat Michael Goh | អភិបាលឯករាជ្យ (លាលែងនៅថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០២០) |
| លោក ខែក វ៉ារី | អភិបាលឯករាជ្យ |
| លោក Kernem Vidano | អភិបាលឯករាជ្យ (ត្រូវបានតែងតាំងថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២០) |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

អភិបាលដែលបានកាន់តំណែងនៅចុងបញ្ចប់នៃការិយបរិច្ឆេទហិរញ្ញវត្ថុនិងជាភាគទុនិករបស់ធនាគារមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **អ្នកឧកញ៉ា លី ហួរ** | ២២.៥០០.០០០ | ១៦.៤០២.០៧១ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជា ភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃទៀត ។

នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានអភិបាលរបស់ធនាគារណាម្នាក់បានទទួលឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ(ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបដែលបានទទួល ឬដល់កាលកំណត់

ដែលនឹងត្រូវទទួលបានដោយក្រុមប្រឹក្សាភិបាលដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនណាមួយ ដែល ក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះ ឬក៏ធ្វើឡើងជាមួយធនាគារណាមួយ ដែលអភិបាលនោះមាន ភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេលើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុរៀបចំឡើងយ៉ាង ត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្នហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

(ខ) អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ គឺត្រូវតែបង្ហាញ ពន្យល់ និង កំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាន និរន្តរភាពនៃគណនេយ្យលើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យនិងដឹកនាំធនាគារឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា កិច្ចការ នេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តតាមនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី ១១ ដល់ទី ១០៦ ថាបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ។

ចុះហត្ថលេខាជំនួសឲ្យក្រុមប្រឹក្សាភិបាល

**អ្នកឧកញ៉ា លី ហួរ**
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៖ ២៩ ខែ មីនា ឆ្នាំ ២០២១

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក (ពីមុនត្រូវបានគេស្គាល់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី)

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក (ពីមុនត្រូវបានគេស្គាល់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី) ("ធនាគារ") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី ១១ ដល់ទី ១០៦ (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ខែធ្នូឆ្នាំ២០២០ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរទឹកប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក.") ។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុង កថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីធនាគារដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍របស់ក្រុម ប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី ១ ដល់ទី ៦ និងរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ ។ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗហើយពិចារណាថាតើព័ត៌មានផ្សេងៗនេះមានអសង្គតិភាពជាសារវន្តជាមួយនឹង របាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬក៏ពត៌មានផ្សេងៗនេះបង្ហាញនូវកំហុងឆ្គងជាសារវន្ត ។

ប្រសិនបើផ្អែកទៅលើការអានព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្ម អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយ និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ធនាគារ ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយ សារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គង តែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការ វិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នាការលួចបន្លំការលុបចោលដោយចេតនាការបកស្រាយមិនពិតឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងដើម្បី រៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលធនាគារបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃគណនេយ្យរបស់អ្នកគ្រប់គ្រងហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្តយើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មាន ពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈ មិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។
- ធ្វើការវាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**




**ហ្គេក ទាវ**
Partner
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៖ ២៩ ខែ មីនា ឆ្នាំ ២០២១

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៤.៩៨៣.២៥៧ | ៦០.៦០៧.២៧៤ | ៤៩.២៤៣.៤៤២ | ២០០.៦៦៧.០២៦ |
| ប្រាក់តម្កល់តាមច្បាប់ | ១២.៧៧៤.៣៦៤ | ៥១.៦៧២.៣០២ | ៨០០.០០០ | ៣.២៦០.០០០ |
| ឥណទានផ្តល់ដល់អតិថិជន | ១៩៥.២៩៣.៣១២ | ៧៨៩.៩៦១.៤៤៧ | ៩៧.៣៩៧.៤០២ | ៣៩៦.៨៩៤.៤១៣ |
| ទ្រព្យសកម្មផ្សេងៗ | ៩៦២.៧៤៣ | ៣.៨៩៤.២៩៦ | ២២២.២៣៦ | ៩០៥.៦១១ |
| ទ្រព្យសកម្មអរូបី | ២.៥៣៦.៧១២ | ១០.២៦១.០០០ | ១៥១.៦៧០ | ៦១៨.០៥៥ |
| ទ្រព្យ និងបរិក្ខារ | ៥.៦០៣.៩២៩ | ២២.៦៦៧.៨៩៣ | ៩៣៤.៥៤៣ | ៣.៨០៨.២៦៣ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១១.១៦៦.០១០ | ៤៥.១៦៦.៥១០ | ៤.២១៩.៥០២ | ១៧.១៩៤.៤៧១ |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | ៤៦៣.៩៤៨ | ១.៨៧៦.៦៧០ | ២៥០.៧៤៩ | ១.០២១.៨០២ |
| **ទ្រព្យសកម្មសរុប** | ២៤៣.៧៨៤.២៧៥ | ៩៨៦.១០៧.៣៩២ | ១៥៣.២១៩.៥៤៤ | ៦២៤.៣៦៩.៦៤១ |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១១៩.៥៣៤.១៨៤ | ៤៨៣.៥១៥.៧៧៤ | - | - |
| ប្រាក់កម្ចី | ៣៦.៩៥៧.០១៧ | ១៤៩.៤៩១.១៣៤ | ៧៦.៧០៣.៨២៣ | ៣១២.៥៦៨.០៧៩ |
| បំណុលភតិសន្យា | ១១.០៣៦.៨៣១ | ៤៤.៦៤៣.៩៨១ | ៤.១៣០.៥៨៥ | ១៦.៨៣២.១៣៤ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | ៩៤.០១០ | ៣៨០.២៧០ | ៩៣.៩១៤ | ៣៨២.៧០០ |
| បំណុលផ្សេងៗ | ២៥២.៧២៣ | ១.០២២.២៦៥ | ១.២៥៦.៤៧១ | ៥.១២០.១១៨ |
| បំណុលពន្ធអប្បបរមា | ២៤.៥០៩ | ៩៩.១៣៩ | - | - |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | - | - | ៤៦៥.៣៣៤ | ១.៨៩៦.២៣៦ |
| បំណុលសរុប | ១៦៧.៨៩៩.២៧៤ | ៦៧៩.១៥២.៥៦៣ | ៨២.៦៥០.១២៧ | ៣៣៦.៧៩៩.២៦៧ |
| **មូលធន** | | | | |
| ដើមទុន | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ៦៨.៩០២.០៧១ | ២៧៨.៣៥៧.៣២៣ |
| ទុនបម្រុងកាតព្វកិច្ច | ១១៣.២២០ | ៤៥៨.៧៦៧ | ១១៣.២២០ | ៤៥៨.៧៦៧ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៣.០៤៨.៦៩៦ | ១២.៣៨៦.២១៦ | ១.៤១១.៥៩៨ | ៥.៧១១.៧៦៧ |
| (ប្រាក់ខាតបង្គរ)/ប្រាក់ចំណេញរក្សាទុក | (២.២៧៦.៩១៥) | (៩.៣០៩.៨៥០) | ១៤២.៥២៨ | ៥៥៤.២១៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៣៦៥.៧៦១ | - | ២.៤៨៨.២៩៨ |
| **មូលធនសរុប** | ៧៥.៨៨៥.០០១ | ៣០៦.៩៥៤.៨២៩ | ៧០.៥៦៩.៤១៧ | ២៨៧.៥៧០.៣៧៤ |
| **បំណុល និង មូលធនសរុប** | ២៤៣.៧៨៤.២៧៥ | ៩៨៦.១០៧.៣៩២ | ១៥៣.២១៩.៥៤៤ | ៦២៤.៣៦៩.៦៤១ |

***កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ចំណូលពីប្រតិបត្តិការ** | | | | |
| ចំណូលពីការប្រាក់ | ១៨.៦០១.៦៧៥ | ៧៥.៨៣៩.០២៩ | ១៥.២៣៤.៥៧៣ | ៦១.៧៣០.៤៩០ |
| ចំណាយលើការប្រាក់ | (៦.៤៥០.៧១៨) | (២៦.២៩៩.៥៧៧) | (៦.២៧៣.៥៨០) | (២៥.៤២០.៥៤៦) |
| **ចំណូលពីការប្រាក់សុទ្ធ** | ១២.១៥០.៩៥៧ | ៤៩.៥៣៩.៤៥២ | ៨.៩៦០.៩៩៣ | ៣៦.៣០៩.៩៤៤ |
| ចំណូលសុទ្ធពីប្រាក់កម្រៃ និងជើងសារ | ៣៤០.៩១៤ | ១.៣៨៩.៩០៧ | ៣៤២.១០៥ | ១.៣៨៦.២០៩ |
| ចំណូលផ្សេងៗ | ៣១៤.៥៣៨ | ១.២៨២.៣៧១ | ៧០១.៣៦១ | ២.៨៤១.៩១៥ |
| **ចំណេញពីប្រតិបត្តិការសរុប** | ១២.៨០៦.៤០៩ | ៥២.២១១.៧៣០ | ១០.០០៤.៤៥៩ | ៤០.៥៣៨.០៦៨ |
| ចំណាយលើបុគ្គលិក | (៧.៣១៨.១៧៨) | (២៩.៨៣៦.២១២) | (៤.០៥៩.៩៩១) | (១៦.៤៥១.០៨៤) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៥.៤៦៩.០១៧) | (២២.២៩៧.១៨២) | (៣.០៥៣.៣២៩) | (១២.៣៧២.០៨៩) |
| ចំណាយពន្ធអប្បបរមា | (១៩៣.៣៧០) | (៧៨៨.៣៦៩) | - | - |
| **ចំណាយលើប្រតិបត្តិការសរុប** | (១២.៩៨០.៥៦៥) | (៥២.៩២១.៧៦៣) | (៧.១១៣.៣២០) | (២៨.៨២៣.១៧៣) |
| **( ខាត )/ចំណេញមុនដកឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ** | (១៧៤.១៥៦) | (៧១០.០៣៣) | ២.៨៩១.១៣៩ | ១១.៧១៤.៨៩៥ |
| ការខាតបង់លើឱនភាពនៃតម្លៃ ឧបករណ៍ហិរញ្ញវត្ថុ | (៨២១.៣៨៨) | (៣.៣៤៨.៧៩៩) | (៥.៨៤៩) | (២៣.៧០០) |
| **ប្រាក់( ខាត )/ចំណេញសុទ្ធមុនដកពន្ធលើប្រាក់ចំណេញ** | (៩៩៥.៥៤៤) | (៤.០៥៨.៨៣២) | ២.៨៨៥.២៩០ | ១១.៦៩១.១៩៥ |
| អត្ថប្រយោជន៍/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ២១៣.១៩៩ | ៨៦៩.២១២ | (៦២០.៨៩២) | (២.៥១៥.៨៥៤) |
| **( ខាត )/ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | (៧៨២.៣៤៥) | (៣.១៨៩.៦២០) | ២.២៦៤.៣៩៨ | ៩.១៧៥.៣៤១ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២.១២២.៥៣៧) | - | ២.៣២៨.៣៦៥ |
| **លទ្ធផល( ខាត )/ចំណេញលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | (៧៨២.៣៤៥) | (៥.៣១២.១៥៧) | ២.២៦៤.៣៩៨ | ១១.៥០៣.៧០៦ |

***កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ដើមទុន | | ទុនបម្រុងកាតព្វកិច្ច | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ១៦.០០០.០០០ | ៦៤.០០០.០០០ | ២៦៧.០១២ | ១.០៨០.០៦៤ |
| **ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនរបស់ធនាគារ** | | | | |
| ការបោះផ្សាយភាគហ៊ុន | ៤៧.៥៦១.៨៣៥ | ១៩២.៧២០.៥៥៥ | - | - |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅដើមទុន | ៥.៣៤០.២៣៦ | ២១.៦៣៦.៧៦៨ | (២៦៧.០១២) | (១.០៨០.០៦៤) |
| | ៦៨.៩០២.០៧១ | ២៧៨.៣៥៧.៣២៣ | - | - |
| **ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងកាតព្វកិច្ច | - | - | ១១៣.២២០ | ៤៥៨.៧៦៧ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - |
| **លទ្ធផលលម្អិត** | | | | |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - |
| | - | - | - | - |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ៦៨.៩០២.០៧១ | ២៧៨.៣៥៧.៣២៣ | ១១៣.២២០ | ៤៥៨.៧៦៧ |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ៦៨.៩០២.០៧១ | ២៧៨.៣៥៧.៣២៣ | ១១៣.២២០ | ៤៥៨.៧៦៧ |
| **ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនរបស់ធនាគារ** | | | | |
| ការបោះផ្សាយភាគហ៊ុន | ៦.០៩៧.៩២៩ | ២៤.៦៩៦.៦១២ | - | - |
| | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ១១៣.២២០ | ៤៥៨.៧៦៧ |
| **ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - |
| **លទ្ធផលលម្អិត** | | | | |
| ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - |
| | - | - | - | - |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ១១៣.២២០ | ៤៥៨.៧៦៧ |

***កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

| ទុនបម្រុងតាមបទប្បញ្ញត្តិ | | (ប្រាក់ខាតបង្គរ)/ ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|
| ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ១.១៤៦.៨៤៣ | ៤.៦៣៨.៩៨០ | ៣.៣២៩.៣២៩ | ១៣.៤៦៧.១៣៦ | - | ១៥៩.៩៣៣ | ២០.៧៤៣.១៨៤ | ៨៣.៣៤៦.១១៣ |
| - | - | - | - | - | - | ៤៧.៥៦១.៨៣៥ | ១៩២.៧២០.៥៥៥ |
| - | - | (៥.០៧៣.២២៤) | (២០.៥៥៦.៧០៤) | - | - | - | - |
| ១.១៤៦.៨៤៣ | ៤.៦៣៨.៩៨០ | (១.៧៤៣.៨៩៥) | (៧.០៨៩.៥៦៨) | - | ១៥៩.៩៣៣ | ៦៨.៣០៥.០១៩ | ២៧៦.០៦៦.៦៦៨ |
| - | - | (១១៣.២២០) | (៤៥៨.៧៦៧) | - | - | - | - |
| ២៦៤.៧៥៥ | ១.០៧២.៨៤៧ | (២៦៤.៧៥៥) | (១.០៧២.៨៤៧) | - | - | - | - |
| - | - | ២.២៦៤.៣៩៨ | ៩.១៧៥.៣៤១ | - | - | ២.២៦៤.៣៩៨ | ៩.១៧៥.៣៤១ |
| - | - | - | - | - | ២.៣២៨.៣៦៥ | - | ២.៣២៨.៣៦៥ |
| - | - | ២.២៦៤.៣៩៨ | ៩.១៧៥.៣៤១ | - | ២.៣២៨.៣៦៥ | ២.២៦៤.៣៩៨ | ១១.៥០៣.៧០៦ |
| ១.៤១១.៥៩៨ | ៥.៧១១.៧៦៧ | ១៤២.៥២៨ | ៥៥៤.២១៩ | - | ២.៤៨៨.២៩៨ | ៧០.៥៦៩.៤១៧ | ២៨៧.៥៧០.៣៧៤ |
| ១.៤១១.៥៩៨ | ៥.៧១១.៧៦៧ | ១៤២.៥២៨ | ៥៥៤.២១៩ | - | ២.៤៨៨.២៩៨ | ៧០.៥៦៩.៤១៧ | ២៨៧.៥៧០.៣៧៤ |
| - | - | - | - | - | - | ៦.០៩៧.៩២៩ | ២៤.៦៩៦.៦១២ |
| ១.៤១១.៥៩៨ | ៥.៧១១.៧៦៧ | ១៤២.៥២៨ | ៥៥៤.២១៩ | - | ២.៤៨៨.២៩៨ | ៧៦.៦៦៧.៣៤៦ | ៣១២.២៦៦.៩៨៦ |
| ១.៦៣៧.០៩៨ | ៦.៦៧៤.៤៤៩ | (១.៦៣៧.០៩៨) | (៦.៦៧៤.៤៤៩) | - | - | - | - |
| - | - | (៧៨២.៣៤៥) | (៣.១៨៩.៦២០) | - | - | (៧៨២.៣៤៥) | (៣.១៨៩.៦២០) |
| - | - | - | - | - | (២.១២២.៥៣៧) | - | (២.១២២.៥៣៧) |
| - | - | (៧៨២.៣៤៥) | (៣.១៨៩.៦២០) | - | (២.១២២.៥៣៧) | (៧៨២.៣៤៥) | (៥.៣១២.១៥៧) |
| ៣.០៤៨.៦៩៦ | ១២.៣៨៦.២១៦ | (២.២៧៦.៩១៥) | (៩.៣០៩.៨៥០) | - | ៣៦៥.៧៦១ | ៧៥.៨៨៥.០០១ | ៣០៦.៩៥៤.៨២៩ |

# របាយការណ៍លំហូរទឹកប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| (ខាត)/ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | (៧៨២.៣៤៥) | (៣.១៨៩.៦២០) | ២.២៦៤.៣៩៨ | ៩.១៧៥.៣៤១ |
| **និយ័តកម្មលើ**: | | | | |
| (អត្ថប្រយោជន៍)/ចំណាយពន្ធលើប្រាក់ចំណេញ | (២១៣.១៩៩) | (៨៦៩.២១២) | ៦២០.៨៩២ | ២.៥១៥.៨៥៤ |
| ចំណាយពន្ធអប្បបរមា | ១៩៣.៣៧០ | ៧៨៨.៣៦៩ | - | - |
| រំលស់ | ១.៦៩០.៣៧៤ | ៦.៨៩១.៦៥៤ | ៩៥៧.៦៥៧ | ៣.៨៨០.៤២៦ |
| ការលុបចោលនៃទ្រព្យ និងបរិក្ខារ | - | - | ១៤៥ | ៥៨៨ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | ៣១៥.១២១ | ១.២៨៤.៧៤៨ | ១២៤.៦២៣ | ៥០៤.៩៧២ |
| ចំណូលសុទ្ធពីការប្រាក់ | (១២.១៥០.៩៥៧) | (៤៩.៥៣៩.៤៥២) | (៨.៩៦០.៩៩៣) | (៣៦.៣០៩.៩៤៤) |
| ការខាតបង់លើឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ | ៨២១.៣៨៨ | ៣.៣៤៨.៧៩៩ | ៥.៨៤៩ | ២៣.៧០០ |
| | (១០.១២៦.២៤៨) | (៤១.២៨៤.៧១៤) | (៤.៩៨៧.៤២៩) | (២០.២០៩.០៦៣) |
| **បម្រែបម្រួលនៃ**: | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (៩៨.១១៦.២០៨) | (៤០០.០១៩.៧៨០) | (២១.៣៥៦.០៥០) | (៨៦.៥៣៤.៧១៥) |
| ប្រាក់បញ្ញើរបស់អតិថិជន | ១១៨.៧២៥.១៩៩ | ៤៨៤.០៤២.៦៣៦ | - | - |
| ទ្រព្យសកម្មផ្សេងៗ | (១.៣៣១.៨១៤) | (៥.៤២៩.៨០៦) | (២០៦.៩៥៩) | (៨៣៨.៥៩៨) |
| បំណុលផ្សេងៗ | (១.០០៣.៧៤៨) | (៤.០៩២.២៨១) | ១០៩.៣១៩ | ៤៤២.៩៦១ |
| **សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង)ប្រតិបត្តិការ** | ៨.១៤៧.១៨១ | ៣៣.២១៦.០៥៥ | (២៦.៤៤១.១១៩) | (១០៧.១៣៩.៤១៥) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | (៣១៥.០២៥) | (១.២៨៤.៣៥៧) | (១៩៣.៥៧៥) | (៧៨៤.៦៨៤) |
| ចំណូលការប្រាក់បានទទួល | ១៨.០៥៨.៦៣៤ | ៧៣.៦២៥.០៥១ | ១៥.២៣៤.៥៧៣ | ៦១.៧៣០.៤៩០ |
| ចំណាយការប្រាក់បានបង់ | (៤.៨៧១.១៨៨) | (១៩.៨៥៩.៨៣៣) | (៥.៩៩៦.៨២៦) | (២៤.២៩៩.១៣៩) |

***កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

## របាយការណ៍លំហូរទឹកប្រាក់ ( ត )

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធលើប្រាក់ចំណេញបានបង់ | (៦៣៤.១៩៥) | (២.៥៨៥.៦១៣) | (៥៨៦.៣៨០) | (២.៣៧៦.០១២) |
| **សាច់ប្រាក់សុទ្ធទទួលបានពី/( ប្រើប្រាស់ក្នុង ) សកម្មភាពប្រតិបត្តិការ** | ២០.៣៨៥.៤០៧ | ៨៣.១១១.៣០៣ | (១៧.៩៨៣.៣២៧) | (៧២.៨៦៨.៧៦០) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | (៧.៤២៩.២២៥) | (៣០.២៨៨.៩៥០) | (៦៩៨.១០១) | (២.៨២៨.៧០៥) |
| ប្រាក់តម្កល់តាមច្បាប់ | (១១.៩៧៤.៣៦៤) | (៤៨.៨១៩.៤៨២) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | (១៩.៤០៣.៥៨៩) | (៧៩.១០៨.៤៣២) | (៦៩៨.១០១) | (២.៨២៨.៧០៥) |
| លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ១៣.៤៦៥.៤០៧ | ៥៤.៨៩៨.៤៦៤ | ៤៩.៣៩៥.៧៥៩ | ២០០.១៥១.៦១៥ |
| ការទូទាត់សងប្រាក់កម្ចី | (៥៣.៣៧៥.៩៦០) | (២១៧.៦១៣.៧៨៩) | (៣៤.៥៧៧.៥១៤) | (១៤០.១០៨.០៨៧) |
| ការទូទាត់បំណុលភតិសន្យា | (១.៣៨៣.៩៧៧) | (៥.៦៤២.៤៧៤) | (៧២៦.៤០៨) | (២.៩៤៣.៤០៥) |
| សាច់ប្រាក់ទទួលបានពីការបង្កើនដើមទុន | ៦.០៩៧.៩២៩ | ២៤.៨៦១.២៥៧ | ៤៧.៥៦១.៨៣៥ | ១៩២.៧២០.៥៥៥ |
| **សាច់ប្រាក់សុទ្ធ( ប្រើប្រាស់ក្នុង )/ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | (៣៥.១៩៦.៦០១) | (១៤៣.៤៩៦.៥៤២) | ៦១.៦៥៣.៦៧២ | ២៤៩.៨២០.៦៧៨ |
| ( **ការថយចុះ** )/**កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (៣៤.២១៤.៧៨៣) | (១៣៩.៤៩៣.៦៧១) | ៤២.៩៧២.២៤៤ | ១៧៤.១២៣.២១៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ | ៤៩.២៤៧.៧២៤ | ២០០.៦៨៤.៤៧៥ | ៦.២៧៥.៤៨០ | ២៥.៤២៨.២៤៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៣៨២.៥៥៨) | - | ១.១៣៣.០១៧ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | ១៥.០៣២.៩៤១ | ៦០.៨០៨.២៤៦ | ៤៩.២៤៧.៧២៤ | ២០០.៦៨៤.៤៧៥ |

### ប្រតិបត្តិការមិនមែនជាសាច់ប្រាក់សំខាន់ៗ៖

នៅក្នុងការិយបរិច្ឆេទ មានប្រតិបត្តិការមិនមែនជាសាច់ប្រាក់សំខាន់ៗ ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក និងទុនបម្រុងកាតព្វកិច្ចទៅដើមទុន | - | - | ៥.៣៤០.២៣៦ | ២១.៦៣៦.៧៦៨ |

***កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។



## SBI Holdings, Inc.

*19F Izumi Garden Tower 1-6-1, Roppongi, Minato-ku, Tokyo 106-6019 Japan*

# ០៣

## បណ្តាញការិយាល័យទំនាក់ទំនង

ការិយាល័យស្តង់ដារ ______ ៤៥
បណ្តាញសាខា ______ ៤៧

សាខាជ្រោយចង្វារ


7.75%
Happy New Year 2020
PHNOM PENH PARK


/ Self-Service Banking
ATM 24/7
ATM / CDM
ATM


SBI LH
10
9
8



Welcome to SBI LH
12
13
SBI LH



បញ្ជរបេឡា / Teller Counter
Welcome to SBI LH
SBI LH
1
2
4
5
6


# ការិយាល័យស្តង់ដារ



SBI LH



C009 9
C008 8
C007 8
C006 9
បញ្ជរបេឡា / Teller Counter
6
7

# បណ្ដាញសាខា

# ២៥

## ខេត្តទូទាំងប្រទេស



## ការិយាល័យកណ្ដាល

អគារលេខ២១៩ ផ្លូវ១២៨ កែង១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ៩៨០ ៨៨៨

អ៊ីម៉ែល : info@sbilhbank.com.kh

គេហទំព័រ : www.sbilhbank.com.kh

## សាខាការិយាល័យ

| | | |
|---|---|---|
| **សាខា ៧មករា** ០១៥ ៨៨៥ ១១៦<br>អគារលេខ២១៩ ផ្លូវ១២៨ កែង១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ | **សាខាទួលគោក** ០១៥ ៨៨៥ ៦៦៧<br>អគារ៨៥-៨៦-៨៧-៨៨ មហាវិថីគីមអ៊ីលស៊ុង (២៨៩) សង្កាត់បឹងកក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ | **សាខាជ្រោយចង្វារ** ០១៦ ៨៨៨ ៧៥១<br>ផ្ទះលេខ អេហ្វ០៦ (បុរីភ្នំពេញថ្មី) ផ្លូវជាតិលេខ៦អា សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |
| **សាខាចំការមន** ០១៥ ៨៨៥ ១២៤<br>អគារលេខ១១៨ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | **សាខាខណ្ឌច្បារអំពៅ** ០១៦ ៨៨៨ ៤០៧<br>ភូមិព្រែកធំ២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ | **សាខាច្បារអំពៅ (២)** ០១៥ ៨៨៥ ១៧២<br>ផ្ទះលេខ២៥ ផ្លូវជាតិលេខ១ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ |
| **សាខាស្រុកកណ្ដាលស្ទឹង** ០១៦ ៨៨៨ ២៩៧<br>ផ្លូវជាតិលេខ៣ ភូមិដើមត្រាំង ឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល | **សាខាស្រុកអង្គស្នួល** ០១៦ ៨៨៨ ៣៧១<br>ផ្ទះលេខ១៨អា១ ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល | **សាខាក្រុងដូនកែវ** ០៨៩ ៦៦៦ ៨១២<br>ភូមិផ្សារតាកោ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ |

| | | |
|---|---|---|
| **សាខាស្រុកបាទី** ០១៦ ៨៨៨ ១៦០<br>អាសយដ្ឋាន ភូមិបរចាម ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ | **សាខាស្រុកត្រាំកក់** ០១៦ ៨៨៨ ២៥៦<br>ផ្លូវជាតិលេខ៣ ភូមិយាយឡ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ | **សាខាស្រុកកោះអណ្តែត** ០១៦ ៨៨៨ ៣៩១<br>ភូមិរមេញខាងជើង ឃុំរមេញ ស្រុកកោះអណ្តែត ខេត្តតាកែវ |
| **សាខាស្រុកគិរីវង់** ០១៥ ៨៨៥ ៣៤៧<br>ភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ | **សាខាស្រុកព្រៃកប្បាស** ០១៦ ៨៨៨ ៤១០<br>ភូមិផ្សារជ្រៃ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ | **សាខាស្រុកកំពង់ត្រាច** ០១៦ ៨៨៨ ៤២០<br>ផ្លូវជាតិលេខ៣១ ភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត |
| **សាខាខេត្តកំពង់ស្ពឺ** ០១៦ ៨៨៨ ២៣៩<br>ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ | **សាខាស្រុកសំរោងទង** ០១៦ ៨៨៨ ២២៧<br>ភូមិត្រពាំងអំពិល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | **សាខាស្រុកព្រៃនប់** ០១៦ ៨៨៨ ៧០១<br>ភូមិសំរុងកណ្តាល ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ |
| **សាខាក្រុងខេមរភូមិន្ទ** ០១៦ ៨៨៦ ៣១៣<br>ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង | **សាខាស្រុកកំពង់ត្រឡាច** ០១៦ ៨៨៥ ៧៥៤<br>ផ្លូវជាតិលេខ៥ ភូមិច្រករមៀត ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | **សាខាស្រុកបាកាន** ០១៦ ៨៨៨ ៤១១<br>ផ្លូវជាតិលេខ៥ ភូមិខ្នាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| **សាខាខេត្តបាត់ដំបង** ០១៥ ៨៨៥ ១៦៦<br>ផ្ទះលេខ៦៣៩ ផ្លូវជាតិលេខ៥ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង | **សាខាស្រុកមោងឫស្សី** ០១៦ ៨៨៨ ៣៦២<br>ផ្លូវជាតិលេខ៥ ភូមិកន្សែបន្ទាយ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង | **សាខាស្រុកបវេល** ០១៦ ៨៨៥ ២២៩<br>ភូមិស្ពានកណ្តាល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង |
| **សាខាស្រុករតនមណ្ឌល** ០១៦ ៨៨៦ ២៥៤<br>ភូមិបាណង់ ឃុំស្តៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង | **សាខាស្រុកភ្នំព្រឹក** ០១៦ ៨៨៦ ២២៨<br>ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង | **សាខាក្រុងសិរីសោភ័ណ** ០១៦ ៨៨៦ ២៤៣<br>ភូមិ៤ សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ |
| **សាខាក្រុងប៉ៃលិន** ០១៧ ៦៥៤ ៨៤២<br>ភូមិអូរតាពុកលើ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន | **សាខាស្រុកអន្លង់វែង** ០១៦ ៨៨៦ ២៨៥<br>ភូមិអូរជញ្ជៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ | **សាខាក្រុងព្រះវិហារ** ០១៦ ៨៨៨ ៥៣៧<br>ភូមិស្រះឈូក សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ |
| **សាខាខេត្តកំពង់ចាម** ០១៦ ៨៨៨ ៤១៩<br>ភូមិបឹងស្នាយ សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម | **សាខាស្រុកបាធាយ** ០១៦ ៨៨៨ ៤៦៦<br>ភូមិផ្អាវ ឃុំផ្អាវ ស្រុកបាធាយ ខេត្តកំពង់ចាម | **សាខាស្រុកជើងព្រៃ** ០១៦ ៨៨៨ ៦៩២<br>ផ្លូវជាតិលេខ៧ ភូមិតាសែន ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម |
| **សាខាក្រុងស្ទឹងសែន** ០១៦ ៨៨៨ ០៦៧<br>ភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | **សាខាស្រុកប្រាសាទបាគង** ០១៦ ៨៨៨ ៥១៥<br>ផ្ទះលេខ៦០-៦១ ផ្លូវជាតិលេខ ៦អា ភូមិគោកត្នោត ឃុំកណ្តែក ស្រុកព្រះបាទបាគង ខេត្តសៀមរាប | **សាខាស្រុកកំពង់ត្របែក** ០១៦ ៨៨៨ ៥១៩<br>ភូមិចំបក់ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង |
| **សាខាស្រុកស្វាយអន្ទរ** ០១៥ ៨៨៥ ៤៧៤<br>ភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង | **សាខាស្រុកព្រះស្តេច** ០១៦ ៨៨៨ ៤០៣<br>ភូមិព្រៃមាស ឃុំអង្គររាជ្យ ស្រុកព្រះស្តេច ខេត្តព្រៃវែង | **សាខាស្រុកពារាំង** ០១៦ ៨៨៧ ១២២<br>ភូមិស្នាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង |
| **សាខាក្រុងបាវិត** ០១៦ ៨៨៥ ១១២<br>ផ្លូវជាតិលេខ១ ភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង | **សាខាស្រុកត្បូងឃ្មុំ** ០១៥ ៨៨៨ ៦២៣<br>ភូមិត្រពាំងគូរ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ | **សាខាក្រុងក្រចេះ** ០១៥ ៨៨៥ ៥៦៥<br>ភូមិអូរឫស្សី១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ |
| **សាខាក្រុងស្ទឹងត្រែង** ០១៦ ៨៨៨ ៤៧៨<br>ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង | **សាខាក្រុងសែនមនោរម្យ** ០១៦ ៨៨៨ ៣៦៥<br>ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី | **សាខាខេត្តរតនគិរី** ០១៦ ៨៨៦ ៣០៨<br>ភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី |

www.sbilhbank.com.kh

**ការិយាល័យកណ្ដាល**
អគារលេខ ២១៩ ផ្លូវ ១២៨ កែង ១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩៨០ ៨៨៨ / info@sbilhbank.com.kh